**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ( សាលាជម្រះក្តី ខេត្ត-ក្រុង )

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ហ៊ុំ រតនា**

**កញ្ញា យិន សុវណ្ណនិស្ស័យ**

សាស្ត្រាចារ្យណែនាំ

**លោក ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **ហ៊ុំ រតនា** និង **យិន សុវណ្ណនិស្ស័យ** ជានិស្សិតនីតិសាស្ត្រ ជំនាន់ទី ១៨ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **អ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើត និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនប្រកប ដោយព្រហ្មវិហារធម៌ និងបានផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរបានរៀនសូត្ររហូតដល់បញ្ចប់ថ្នាក់ បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ១៨នេះ។

យើងខ្ញុំទាំងពីររូប សូមធ្វើថ្លែងអំណរគុណបំផុតចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** ដែលបានផ្តល់លទ្ធភាពឲ្យយើងខ្ញុំបានបន្តការសិក្សា នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាពិសេសបានផ្តល់ឱកាសដល់យើងខ្ញុំទាំងពីររូបអាចចូលរួមសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ហើយយើងខ្ញុំទាំងពីរ ក៏សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកគ្រូ បានចំណាយពេលយ៉ាងមានតម្លៃខិតខំពន្យល់ ណែនាំចែករំលែកបទពិសោធន៍ល្អៗ ជួយកែសម្រួលអក្ខរាវិរុទ្ធ និងការប្រើប្រាស់ពាក្យពេចន៍យ៉ាងច្រើននៅក្នុងអត្ថបទនេះ ដើម្បីជួយជំរុញឲ្យសារណារបស់យើងខ្ញុំទាំងពីររូបសម្រេចបានជាលទ្ធផល។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីររូប សូមគោរពជូនពរចំពោះថ្នាក់ដឹកនាំ បុគ្គលិក និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ឲ្យមានសុខភាពល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ចជានិរន្តរ៍។

# អារម្ភកថា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់បំផុតទៅលើគ្រប់វិស័យនានាជាពិសេស គឺវិស័យអប់រំ។ ការអប់រំ ពិតជាមានសារៈសំខាន់ណាស់សម្រាប់បុគ្គលគ្រប់រូប ដោយការអប់រំជួយឲ្យបុគ្គលម្នាក់ៗ ក្លាយជាបុគ្គលដែលមានការយល់ដឹង មានតម្លៃ សេចក្ដីថ្លៃថ្នូរ ក៏ដូចជាក្លាយជាធនធានសម្រាប់សង្គមជាតិផងដែរ។ រដ្ឋាភិបាលបានបង្កើតឲ្យមានគ្រឹះស្ថានអប់រំសាធារណៈជាច្រើនស្ទើរគ្រប់លំដាប់ថ្នាក់ សម្រាប់បុគ្គល ឬសិស្សនិស្សិតដែលមានបំណងចង់សិក្សាស្វែងយល់ពីជំនាញដែលខ្លួនស្រលាញ់រៀងៗខ្លួន ព្រោះថានៅក្នុងយុគសម័យថ្មីនេះ ចំណេះដឹងគឺជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងសង្គមជាតិ។

ស្របជាមួយគ្នានេះដែរ យើងខ្ញុំទាំងពីរនាក់បានចូលមកសិក្សានៅក្នុង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ ហើយនៅក្នុងសាកលវិទ្យាល័យនេះ គឺពិតជាសាកលវិទ្យាល័យមួយដ៏គួរឲ្យចាប់អារម្មណ៍ ព្រោះសំបូរទៅដោយសាស្ត្រាចារ្យល្បីៗ ដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន និងណែនាំសិស្សនិស្សិតឲ្យយល់ច្បាស់ពីជំនាញ ដែលសិស្សនិស្សិតបានជ្រើសរើសយកមកសិក្សា ក្នុងនោះដែរចំពោះជំនាញដែលយើងខ្ញុំទាំងពីរ បានជ្រើសរើសយកមកសិក្សានោះគឺ ជំនាញផ្នែកនីតិសាស្ត្រ។ ដោយហេតុថានេះជាឆ្នាំបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ នៅសាកលវិទ្យាល័យនេះ ក្រុមយើងខ្ញុំក៏បានសម្រេចជ្រើសរើសយកប្រធានបទមួយ មកធ្វើជាប្រធានសារណាបញ្ចប់ឆ្នាំសិក្សាដែលស្ដីអំពី **«ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្ដីព្រហ្មទណ្ឌ(សាលាដម្រះក្ដី ខេត្ត-ក្រុង)»** ដើម្បីធ្វើជាជំនួយស្មារតី ក៏ដូចជាឯកសារសិក្សាបន្ថែម សម្រាប់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកដែលចង់ស្វែងយល់ពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងនីតិវិធីនៃការស៊ើបសួរ។

យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ គឺនៅមានចំនុចខ្វះចន្លោះ ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យដូចនេះសូមលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការ ស្រាវជ្រាវរបស់ក្រុមយើងខ្ញុំផង ហើយក្រុមយើងខ្ញុំមានសេចក្ដីរីករាយយ៉ាងក្រៃលែង ក្នុងការទទួលនូវយកការរិះគន់ ក្នុង

ន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលំអកិច្ចការស្រាវជ្រាវមួយនេះ អោយកាន់តែមានភាពល្អប្រសើរ។

# មាតិកា

ទំព័រ


សេចក្ដីផ្ដើម..........1

## ជំពូកទី១៖ ការបើកការស៊ើបសួរ

ផ្នែកទី១. សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ..........3

១. និយមន័យ..........3

២. លក្ខណៈសម្បត្តិក្នុងការក្លាយទៅជាចៅក្រមស៊ើបសួរ..........3

៣. ក្រមសីលធម៌ចៅក្រមស៊ើបសួរ..........4

ផ្នែកទី២. ការចាត់តាំងចៅក្រមស៊ើបសួរដោយប្រធានតុលាការ..........4

១. ការចាត់តាំងសំណុំរឿង..........4

២. ការបែងចែកសំណុំរឿង..........5

៣. ការដកហូតសំណុំរឿង..........5

ផ្នែកទី៣. លក្ខណៈពិសេសនៃចៅក្រមស៊ើបសួរ..........5

១. ឯករាជ្យភាពនៃការស៊ើបសួរ..........5

២. អំណាចនៃការចេញដីកាស៊ើបសួរជំនួស..........6

៣. ថិរវេលានៃការស៊ើបសួរ..........6

ផ្នែកទី៤. ការបើកការស៊ើបសួរ..........7

១. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ..........7

២. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី..........8

ផ្នែកទី៥. សមត្ថកិច្ចនៃការបើកការស៊ើបសួរ..........9

១. សមត្ថកិច្ចដែនដី ........ 9

២. សមត្ថកិច្ចសាច់រឿង ........ 10

ជំពូកទី២៖ សមត្ថកិច្ចស្រាវជ្រាវផ្ទាល់របស់ចៅក្រមស៊ើបសួរ

ផ្នែកទី១. ការស្រាវជ្រាវទាក់ទងនឹងបុគ្គល ........ 11

១. ការសួរចម្លើយជនត្រូវចោទ ........ 11

២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ........ 12

៣. ការស្តាប់ចម្លើយសាក្សី ........ 13

ផ្នែកទី២. ការស្រាវជ្រាវទាក់ទងនឹងភស្តុតាង ........ 15

១. ការចុះទៅពិនិត្យដល់កន្លែងកើតហេតុ ........ 15

២. ការឆែកឆេរ និងការចាប់យកភស្តុតាង ........ 15

៣. កោសលវិច័យ ........ 16

៤. ការស្តាប់ទូរស័ព្ទ ........ 18

ផ្នែកទី៣. ការប្រកាសសេចក្តីសម្រេចអំពីការឃុំខ្លួនជនត្រូវចោទ ........ 18

១. ការឃុំខ្លួនតាមការស្នើសុំរបស់អយ្យការ ........ 18

២. ការឃុំខ្លួនតាមគំនិតផ្ទាល់របស់ចៅក្រមស៊ើបសួរ ........ 19

៣. ការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ........ 20

៤. ទណ្ឌកម្មនៃការគេចវេះពីភាតព្វកិច្ចដែលដាក់ចេញដោយតុលាការ ........ 20

ផ្នែកទី៤. នីតិវិធីចាត់អោយស៊ើបជំនួស ........ 21

១. អត្ថន័យ ........ 21

២. បុគ្គលដែលមានសមត្ថកិច្ចក្នុងការស៊ើបជំនួស ........ 22

៣. ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ........ 22

ផ្នែកទី៥. ការប្រគល់វត្ថុចាប់យកឲ្យម្ចាស់វិញ ........ 23

១. នីតិវិធីប្រគល់វត្ថុចាប់យក ........ 23

២. លក្ខខណ្ឌនៃការប្រគល់វត្ថុចាប់យក ........ 24

៣. ការសម្រេចមិនប្រគល់វត្ថុចាប់យក ........ 24

៤. សិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ ........ 24

## ជំពូកទី៣៖ វិធានការនិរន្តរាយ

ផ្នែកទី១. យន្តការបង្គាប់ និងទប់ស្កាត់បទល្មើស ........ 25

១. ដីកាបង្គាប់ឲ្យចូលខ្លួន ........ 25

២. ដីកាបង្គាប់ឲ្យនាំខ្លួន ........ 25

៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន ........ 26

៤. ដីកាបង្គាប់ឲ្យឃុំខ្លួន ........ 28

ផ្នែកទី២. នីតិវិធីពន្យារ និងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 28

១. ការឃុំខ្លួនបណ្ដោះអាសន្ន ........ 28

១.១. គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 28

១.២. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 29

១.៣. មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 29

១.៤. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 30

២. ការត្រួតពិនិត្យតាមផ្លូវច្បាប់តុលាការ ........ 32

២.១. លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវច្បាប់តុលាការ ........ 32

២.២. បុគ្គលដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ 33

២.៣. អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........ 34

## ជំពូកទី៤៖ ការបិទការស៊ើបសួរ

ផ្នែកទី១. ការត្រៀមបញ្ចប់នីតិវិធីនៃការបិទការស៊ើបសួរ ........ 35

១. ការជូនពត៌មាននៃការបិទការស៊ើបសួរ ........ 35

២. ការពិនិត្យលើសំណុំរឿងដោយព្រះរាជអាជ្ញា ........ 35

៣.សេចក្ដីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ........ 36

ផ្នែកទី២. ការបិទបញ្ចប់នីតិវិធីស៊ើបសួរ ........ 37

១. ដីកាដំណោះស្រាយ ........ 37

១.១. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ........ 37

១.២. ដីកាសម្រេចលើកលែងការចោទប្រកាន់ ........ 37

២. អានុភាពនៃដីកាដំណោះស្រាយ ........ 38

ផ្នែកទី៣. មោឃភាពនៃការស៊ើបសួរ ........ 39

១. មោឃភាពនៃការមិនគោរពបទបញ្ញត្តិ ........ 39

២. ការប្ដឹងទៅសភាស៊ើបសួរ ........ 40

៣. ការលះបង់ការទាមទារមោឃភាពដោយភាគី ........ 42

៤. ការបើកការស៊ើបសួរលើបន្ទុកថ្មី ........ 43

សេចក្ដីសន្និដ្ឋាន ........ 44

អនុសាសន៍........................................................................................................46
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

នៅជុំវិញពិភពលោកយើងនេះ ក្នុងប្រទេសនីមួយៗគឺតែងតែមានច្បាប់រៀងៗខ្លួនសម្រាប់ធ្វើការគ្រប់គ្រងប្រទេសរបស់ខ្លួនដើម្បីឲ្យប្រទេសមានសណ្តាប់ធ្នាប់ សន្តិសុខ និងរបៀបរៀបរយ ទោះបីជាប្រទេសនោះជាប្រទេសដែលមានរបបដឹកនាំបែបកម្មុយនីស ឬបែបប្រជាធិបតេយ្យក៏ដោយ។ ជាក់ស្តែងប្រទេសកម្ពុជា ជាប្រទេសអធិបតេយ្យមួយ ដែលមានប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងប្រទេសដ៏ល្អ។ ប្រទេសកម្ពុជាបានបង្កើតនូវវិធានច្បាប់នៃការទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្តជាបទល្មើស ដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០១០ ដើម្បីមកផ្តន្ទាទោសតាមច្បាប់។ ក្នុងរឿងក្តីព្រហ្មទណ្ឌនៅពេលដែលមានបទល្មើសកើតឡើង តុលាការ គឺពុំអាចសម្រេចទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួននោះទេ តុលាការត្រូវធ្វើតាមនីតិវិធីដូចដែលមានកំណត់នៅក្នុងក្រមនីតិវិធីឆ្នាំ២០០៧ ដើម្បីស្វែងរកឲ្យឃើញការពិតនូវបទល្មើស ហើយមន្ត្រីដែលមានសមត្ថកិច្ចមានមន្ត្រីនគរបាលយុត្តិធម៌ បន្ទាប់មកព្រះរាជអាជ្ញា បន្ទាប់មកទៀតចៅក្រមស៊ើបសួរ និងចុងក្រោយគឺទៅជំនុំជម្រះ។

ចំពោះនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ គឺជានីតិវិធីដ៏មានសារៈសំខាន់មួយ ព្រោះចៅក្រមស៊ើបសួរមានតួនាទីដើម្បីស្វែងរកភស្តុតាងដើម្បីដាក់បន្ទុក និងដោះបន្ទុក។ ហេតុដូចនេះហើយទើបក្រុមរបស់យើងខ្ញុំបានលើកយកប្រធានបទមួយស្តីពី **"ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ(សាលាជម្រះក្តី ខេត្ត-ក្រុង)"** មកធ្វើជាប្រធានបទសារណាបញ្ចប់ឆ្នាំសិក្សា ដើម្បីឲ្យអ្នកសិក្សាបានយល់ដឹងថា តើនីតិវិធីនៃការស៊ើបសួរចៅក្រមស៊ើបសួរ ធ្វើឡើងតាមរបៀបណា? តើចៅក្រមស៊ើបសួរមានតួនាទី និងសិទ្ធិអំណាចអ្វីខ្លះ? តើចៅក្រមស៊ើបសួរត្រូវចេញដីកាអ្វីខ្លះ? តើរបៀបនៃការបើក និងការបិទនៃការស៊ើបសួរចៅក្រមត្រូវធ្វើដូចម្តេច?

នៅក្នុងការស្រាវជ្រាវតាក់តែងនូវប្រធានបទនេះឡើងក្នុងគោលបំណង បកស្រាយនូវចម្ងល់ និង ស្វែងយល់អំពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ក៏ដូចជាពង្រីកចំណេះដឹងបន្ថែម និងទុកជាស្នាដៃរបស់ខ្លួនឯង។ ប្រធានបទនេះក្រុមរបស់យើងខ្ញុំបានធ្វើ

ការស្រាវជ្រាវដោយផ្អែកទៅលើច្បាប់ធរមានជាមូលដ្ឋានគឺ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ និងឯកសារពាក់ព័ន្ធផ្សេងទៀតដូចដែលក្រុមរបស់យើងខ្ញុំបានលើកឡើងក្នុងឯកសារយោង។

ប្រធានបទនេះ គឺអាចធ្វើជាឯកសារជំនួយស្មារតី និងជាចំណេះដឹងបន្ថែមទៀតសម្រាប់អ្នកសិក្សា ឬអ្នកដែលចង់ស្វែងយល់ពីចៅក្រមស៊ើបសួរ ក៏ដូចជាពួកខ្ញុំផ្ទាល់ឲ្យបានស្វែងយល់កាន់តែច្បាប់អំពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ នៅក្នុងប្រធានបទនេះផងដែរ ក្រុមយើងខ្ញុំបានលើកយកនូវជំពូកធំៗចំនួន ៤ ដើម្បីយកមកបកស្រាយមានដូចតទៅ៖

- **ជំពូកទី១៖ ការបើកការស៊ើបសួរ**
- **ជំពូកទី២៖ សមត្ថកិច្ចស្រាវជ្រាវផ្ទាល់របស់ចៅក្រមស៊ើបសួរ**
- **ជំពូកទី៣៖ វិធានការនិរន្តរាយ**
- **ជំពូកទី៤៖ ការបិទការស៊ើបសួរ។**

# ជំពូកទី១ ការបើកការស៊ើបសួរ

## ផ្នែកទី១. សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

### ១. និយមន័យ

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាចៅក្រមស៊ើបសួរ គឺបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការស្វែងរកការពិត។ តួនាទីដែលសំខាន់បំផុតរបស់ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នដែលជាសេចក្ដីសម្រេចមានលក្ខណៈប៉ះពាល់ យ៉ាងខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គល។

### ២. លក្ខណៈសម្បត្តិក្នុងការក្លាយទៅជាចៅក្រមស៊ើបសួរ

ដើម្បីក្លាយជាចៅក្រមស៊ើបសួរមួយរូប អ្នកត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោមជាមុន៖

- ត្រូវមានសញ្ជាតិខ្មែរតាំងពីកំណើត
- មានអាយុ ៣៥ (សាមសិបប្រាំ)ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិសិត្ស និងមាន អាយុ ៤០ (សែសិប)ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការគិតដល់ថ្ងៃប្រលង
- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ទៅ
- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

បេក្ខជនដែលប្រលងជាប់ចូលជាសិស្សចៅក្រមនឹងត្រូវទទួលបាន នូវការបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលរៀបចំដោយក្រសួងយុត្តិធម៌ដែលត្រូវបានកំណត់ដោយការប្រកាស។[1]

[1] មាត្រា ១៩ នៃសេចក្ដីព្រាងច្បាប់ស្ដីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤។

**៣. ក្រមសីលធម៌ចៅក្រមស៊ើបសួរ**

ក្រមសីលធម៌ចៅក្រមស៊ើបសួរ គឺជាការតម្រូវឲ្យចៅក្រមស៊ើបសួរដែលបំពេញកិច្ចទាំង ឡាយដោយផ្អែកទៅលើគោលការណ៍ទាំង៥ គឺ៖ គោលការណ៍ឯករាជ គោលការណ៍អនាគតិ (ភាពមិនលំអៀង) គោលការណ៍ភាពសុចរិត គោលការណ៍សេចក្ដីថ្លៃថ្នូរ និងគោលការណ៍វិរិយភាព។[2]

ក្រមសីលធម៌ក៏មានគោលបំណងពង្រឹកនូវឯករាជ្យភាព និងសេចក្ដីថ្លៃថ្នូររបស់ចៅក្រមស៊ើបសួរទាំងអស់ក្នុងការអនុវត្តកិច្ចការតុលាការ ឬអយ្យការ ក៏ដូចជាការប្រកាន់នូវឥរិយាបទរបស់ខ្លួននៅក្រៅតុលាការ។ នៅក្នុងក្រមសីលធម៌នេះ ចៅក្រមមានន័យថា ចៅក្រមអាសនៈ និង ចៅក្រមអយ្យការ។

ក្រមសីលធម៌នេះក៏ជាការបំពេញបន្ថែមពីលើច្បាប់ និងសេចក្ដីណែនាំផ្សេងៗទៀតចំពោះចៅក្រម ដើម្បីបង្កើននូវជំនឿទុកចិត្តពីសាធារណៈជនលើប្រព័ន្ធតុលាការ និងការការពារកេរ្ដិ៍ឈ្មោះរបស់ចៅក្រម។[3]

**ផ្នែកទី២. ការចាត់តាំងចៅក្រមស៊ើបសួរដោយប្រធានតុលាការ**

**១. ការចាត់តាំងសំណុំរឿង**

ចៅក្រមស៊ើបសួរ គឺត្រូវបានតែងតាំងដើម្បីធ្វើការស៊ើបសួរ រឿងក្ដីព្រហ្មទណ្ឌណាមួយតាម សេចក្ដីសម្រេចរបស់ប្រធានតុលាការខេត្ត ឬរាជធានី។ ប៉ុន្តែប្រសិនជាចៅក្រមស៊ើបសួរមានបញ្ហា ដោយសារការឈប់សម្រាក ឬដោយមានជំម្ងឺ ឬដោយមូលហេតុដទៃទៀតពុំអាចបំពេញមុខងាររបស់ខ្លួនបាននោះតុលាការមានសិទ្ធិចាត់តាំងជាបណ្ដោះអាសន្នទៅឲ្យចៅក្រមស៊ើបសួរផ្សេងទៀតឲ្យមកបំពេញមុខងារនេះ ហើយចំពោះដីកាចាត់តាំងនេះគឺពុំបើកផ្លូវតវ៉ា។[4]

---

[2] ក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៤។

[3] ប្រការ ១ នៃក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៤។

[4] មាត្រា ៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

**២. ការបែងចែកសំណុំរឿង**

កាលណាមានចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងតុលាការមួយ សំណុំរឿងទាំងឡាយត្រូវធ្វើការបែកចែកដោយប្រធានតុលាការ ដែលធ្វើការបែងចែករៀងរាល់ឆ្នាំម្តង។[5]

ការបែងចែកសំណុំរឿងនេះ គឺត្រូវធ្វើឡើងទៅតាមលំដាប់លេខរៀងរបស់ចៅក្រមម្នាក់ៗ ដែលពុំមានសិទ្ធិធ្វើការផ្លាស់ប្តូរនៅក្នុងឆ្នាំនោះឡើយ។ ប៉ុន្តែក៏មានករណីលើកលែងដោយមូលហេតុចៅក្រមរូបនោះមានការងារច្រើនពេក ឬក៏ត្រូវប្តូរទៅតុលាការផ្សេងទៀត។ នៅក្នុងករណីនេះប្រធានតុលាការត្រូវចេញដីកាចាត់តាំងមួយថ្មីទៀត។

**៣. ការដកហូតសំណុំរឿង**

ដើម្បីធ្វើការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ប្រគល់ទៅឲ្យចៅក្រមស៊ើបសួរម្នាក់ទៀតអ្នកត្រូវតែធ្វើពាក្យស្នើសុំទៅប្រធានតុលាការ ដោយការស្នើសុំនេះតម្រូវឲ្យធ្វើឡើងដោយមានពាក្យសុំដែលជាសំអាងរបស់ព្រះរាជអាជ្ញា (ចៅក្រមអយ្យការ)។ លើសពីនេះការដកហូតសំណុំរឿងត្រូវតែមានការបញ្ជាក់អំពីមូលហេតុឲ្យបានច្បាស់លាស់ ដូចជាចៅក្រមស៊ើបសួរ ឬសហព័ទ្ធរបស់ចៅក្រម ឬចៅក្រមជាញាតិលោហិតរបស់ភាគីណាមួយដូចដែលបានចែងនៅក្នុងមាត្រ ៥៥៦ (មូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ)។[6]

## **ផ្នែកទី៣. លក្ខណៈពិសេសនៃចៅក្រមស៊ើបសួរ**

**១. ឯករាជ្យភាពនៃការស៊ើបសួរ**

ជាគោលការណ៍ព្រះរាជអាជ្ញា មានសេរីភាពពេញលេញក្នុងការសម្រេចការចោទប្រកាន់ ឬមិនមិនចោទប្រកាន់។ ប៉ុន្តែដោយហេតុថាព្រះរាជអាជ្ញាស្ថិតនៅក្នុងអង្គដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញាត្រូវតែធ្វើតាមបង្គាប់របស់ថ្នាក់លើតាមឋានានុក្រមរបស់ខ្លួនដែលបង្គាប់ឲ្យធ្វើការ ចោទប្រកាន់លើអំពើអ្វីមួយ ទោះបីជាព្រះរាជអាជ្ញាខ្លួនឯងយល់ឃើញថាពុំត្រូវចោទប្រកាន់ក៏ដោយ។ គួរបញ្ជាក់ដែរថា មានតែបញ្ជាឲ្យចោទប្រកាន់ប៉ុណ្ណោះដែលព្រះរាជអាជ្ញាត្រូវអនុវត្តន៍តាម តែប្រសិនបើមានបញ្ជាមិនឲ្យចោទប្រកាន់ តែព្រះរាជអាជ្ញាបានចោទប្រកាន់រួចទៅហើយ គឺព្រះរាជអាជ្ញាពុំអាចដកហូតការចោទប្រកាន់របស់ខ្លួនបាន

---

[5] មាត្រា ៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[6] មាត្រា ៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ទេ។[7] ប៉ុន្តែយ៉ាងណាក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវធ្វើការស៊ើបសួរដោយមានលក្ខណៈឯករាជ្យយ៉ាងពិតប្រាកដ បើទោះបីជាការបើកការស៊ើបសួររបស់គាត់ គឺយោងទៅតាមដីការបស់ព្រះរាជអាជ្ញា ឬតាមការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ តែគាត់នៅតែមានសិទ្ធិធ្វើនូវសេចក្ដីសម្រេចមួយដែលវាអាចមានលក្ខណៈសមស្រប ឬ ផ្ទុយនឹងដីការបស់ព្រះរាជអាជ្ញាតាមរយៈដីកាដំណោះស្រាយ។[8]

### ២. អំណាចនៃការចេញដីកាស៊ើបសួរជំនួស

តាមរយៈដីកាចាត់ឲ្យមានការស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិទៅឲ្យចៅក្រម នៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។[9] ដូចគ្នានេះផងដែរ ដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវតែបញ្ជាក់អំពីកិច្ចដែលត្រូវធ្វើ ដែលកិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលត្រូវចោទប្រកាន់។ គួរបញ្ជាក់ផងដែរថា ដីកាចាត់ឲ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅបានទេវាត្រូវតែមានការណែនាំឲ្យបានច្បាស់លាស់។[10]

### ៣. ថិរវេលានៃការស៊ើបសួរ

ចំពោះថិរវេលានៃការស៊ើបសួរ គឺពុំមានច្បាប់ណាដែលបានចែងអំពីថិរវេលាណាមួយកំណត់ជាក់លាក់ឡើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធានាឲ្យបាននូវសិទ្ធិរបស់ជនត្រូវចោទ ច្បាប់ក៏បានផ្ដល់សិទ្ធិទៅឲ្យជនត្រូវចោទ ដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នក្នុងការប្ដឹងមកចៅក្រមស៊ើបសួរ ក្នុងគោលបំណង ចង់ឲ្យសម្រេចបិទបញ្ចប់នៃការស៊ើបសួរប្រសិនបើហួសរយៈពេល ១ឆ្នាំ។[11]

---

[7] មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[8] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[9] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[10] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[11] មាត្រា ២៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

**ផ្នែកទី៤. ការបើកការស៊ើបសួរ**

ការបើកឲ្យមានការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ដីកាបញ្ជូនរឿងឲ្យមានការស៊ើបសួរ ត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌគឺ៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស (ឧទាហរណ៍: អំពើលួច, ឃាតកម្ម ជាដើម)
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន (នៅក្នុងករណីមិនអាច កំណត់បានអាចធ្វើការបើកស៊ើបសួរប្រឆាំងនិងអញ្ញាតជន ពោលគឺជនមិនស្គាល់)
- ចុះកាលបរិច្ឆេទ និងហត្ថលេខា។

**១. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាការបើកការស៊ើបសួរដោយព្រះរាជអាជ្ញា ការស៊ើបសួរនេះផងដែរអាចបើកប្រឆាំងទៅនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន (ជនដែលមិនមានឈ្មោះ ឬ ភិនភាគ)។

ក្រោយពេលដែលចៅក្រមស៊ើបសួរទទួលបានបណ្តឹងរបស់ព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួចមក ចៅក្រមស៊ើបសួរត្រូវធ្វើការស៊ើបសួរទៅតាមការចង្អុលបង្ហាញរបស់ព្រះរាជអាជ្ញានៅក្នុងដីកា។

ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាបានឡើយ។[12]

[12] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ២. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹងរបស់ជនរងគ្រោះ គឺជាបណ្ដឹងដែលជនរងគ្រោះធ្វើឡើងដើម្បីទទួលបានការជួសជុលព្យសនកម្មផ្ទាល់ខ្លួននៅនាពេលបច្ចុប្បន្ន។ ព្យសនកម្ម អាចជាព្យសនកម្មខាងសំភារៈរូបរាងកាយ និងផ្លូវចិត្ត។[13]

ចៅក្រមស៊ើបសួរ តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយខ្លួនឯងផ្ទាល់ ឬក៏ មានអ្នកតំណាង។ ទោះបីជាចៅក្រមស៊ើបសួរទទួលពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីអយ្យការជាមុនសិន ទើបអាចធ្វើការស៊ើបសួរបាន។ ក្នុងន័យនេះដែរក្រោយពីបានទទួលពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់ការដាក់ពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា ហើយបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា។[14] ពេលដែលទទួលបានការបញ្ជូននេះ ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមដីកាបញ្ជូនរឿងក្ដីឲ្យស៊ើបសួរ ប៉ុន្តែព្រះរាជអាជ្ញា ក៏សុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

នៅក្នុងករណី ដែលព្រះរាជអាជ្ញាបានស្នើសុំកុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ចៅក្រមស៊ើបសួរអាចមានជម្រើសពីរយ៉ាងគឺ៖

- មិនធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចសំអាងហេតុ ហើយធ្វើការជូនដំណឹងទៅដើម បណ្ដឹងរដ្ឋប្បវេណី។
- ធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចមានអំអាងហេតុ ហើយធ្វើការជូនដំណឹងទៅព្រះរាជអាជ្ញា។

គួរតែកត់សម្គាល់ដែរថា បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលជាដើមបណ្ដឹងមួយថ្មីដែលទើបតែបញ្ចូលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះឯង ហើយ

[13] មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[14] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់នូវប្រាក់តម្កល់ទុក តាមការកំណត់របស់ចៅក្រមស៊ើបសួរតាម ដីកាសម្រេច ដោយផ្អែកលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងក្តីដែលអាចមើលឃើញជាមុន តែចៅក្រមស៊ើបសួរក៏អាចលើកលែងមិនឲ្យបង់ប្រាក់បានដែរ។ ប្រសិនបើចៅក្រមស៊ើបសួរតម្រូវឲ្យមានការបង់ប្រាក់តម្កល់ទុក តែដើមបណ្តឹងរដ្ឋប្បវេណីមិនព្រមបង់ក្នុងរយៈពេលកំណត់ដោយចៅក្រមទេ នោះចៅក្រមស៊ើបសួរត្រូវប្រកាសថាមិនអាចទទួលពាក្យបណ្តឹងនេះបាន។ ការតម្រូវឲ្យមានការបង់ប្រាក់តម្កល់ទុកគឺដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណី ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា ចៅក្រមស៊ើបសួរចេញដីកាសម្រេចឲ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី[15] តែប្រាក់ពិន័យនេះពុំអាចលើសពីចំនួនទឹកប្រាក់តម្កល់ទុកបានឡើយ។ ផ្ទុយទៅវិញប្រសិនបើពុំត្រូវបង់ប្រាក់ពិន័យរដ្ឋប្បវេណីទេ ប្រាក់តម្កល់ទុកនេះត្រូវបង្វិលទៅឲ្យសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី។[16]

### ផ្នែកទី៥. សមត្ថកិច្ចនៃការបើកការស៊ើបសួរ

សមត្ថកិច្ចនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរមាន ២ប្រភេទគឺ:

**១. សមត្ថកិច្ចដែនដី**

ចៅក្រមស៊ើបសួរស្ថិតនៅជាមួយសាលាដំបូង ដូច្នេះគាត់មានសមត្ថកិច្ចក្នុងដែនសមត្ថកិច្ចរបស់តុលាការនេះ នូវចំពោះគ្រប់បទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចនោះ និងចំពោះបទល្មើសដែលកើតឡើងនៅក្រៅដែនសមត្ថកិច្ច ប្រសិនបើជនសង្ស័យម្នាក់ថាបានចូលរួមប្រព្រឹត្តបទល្មើសទាំងអស់រស់នៅ ឬត្រូវបានចាប់ក្នុងដែនសមត្ថកិច្ចរបស់គាត់ទោះជាត្រូវចាប់មូលហេតុផ្សេងក៏ដោយ។

សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរមាន:

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស

[15] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[16] មាត្រា ១៩០ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបាន ប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យ ថាបានប្រព្រឹត្តបទល្មើស។

ប្រសិនបើមានទំនាស់សមត្ថកិច្ចរវាងចៅក្រមស៊ើបសួរនៃសាលាដំបូងខុសគ្នា ដែលទទួលបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា។ ដូចនេះប្រធានសភាស៊ើបសួរជាអ្នកធ្វើការសម្រេចដែលវាជាការសម្រេចបិទផ្លូវតវ៉ា។[17]

**២. សមត្ថកិច្ចសាច់រឿង**

ចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរទៅបានក៏ត្រូវតែមានដែនកំណត់ ក៏ដូចជាទៅតាមប្រភេទនៃរឿងផងដែរ។ ករណីមានបណ្តឹងពីព្រះរាជអាជ្ញា ឬដោយជនរងគ្រោះតាមរយៈបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅចៅក្រមស៊ើបសួរ ឬ ចំពោះបទឧក្រិដ្ឋ ចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរជាដាច់ខាតទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និង ចំពោះការស៊ើបសួរក្នុងបទមជ្ឈិមវិញអាចត្រូវធ្វើ ឬមិនត្រូវធ្វើក៏បាន។[18]

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានទេ។ កាលណាចៅក្រមស៊ើបសួរ ទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចដែលមានចែងនៅមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។ កាលណាទទួលពាក្យបណ្តឹងសាមញ្ញចៅក្រមស៊ើបសួរត្រូវតែបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា។[19]

[17] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[18] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[19] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

# ជំពូកទី២ សមត្ថកិច្ចស្រាវជ្រាវផ្ទាល់របស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១. ការស្រាវជ្រាវទាក់ទងនឹងបុគ្គល

### ១. ការសួរចម្លើយជនត្រូវចោទ

នៅក្នុងកិច្ចនេះសំដៅទៅលើការសួរចម្លើយបុគ្គលដែលមានពិរុទ្ធរួចហើយ និងចោទគ្រប់សួរសំនួរដែលចាំបាច់ក្នុងការបង្ហាញការពិត ហើយពេលចូលខ្លួនលើកដំបូងចៅក្រមស៊ើបសួរត្រូវសួរ និងកត់ត្រាអំពីអត្តសញ្ញាណជនត្រូវចោទនោះដូចជាឈ្មោះ អាយុ សញ្ញាតិ ភេទ លំនៅឋាន ឬមុខរបរជាដើម។ ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទឲ្យដឹងរឿងរ៉ាវដែលចោទប្រកាន់ នឹងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។[20] ជនត្រូវចោទក៏មានសិទ្ធិក្នុងការជ្រើសរើសមេធាវី ឬ សុំអោយតុលាការចាត់តាំងមេធាវីអោយខ្លួន ហើយចំពោះការចាត់តាំងមេធាវីត្រូវធ្វើដោយប្រធានតុលាការ ក្នុងករណីជនជាប់ចោទជាអនីតិជនគ្មានទីពឹង ជនជាប់ចោទជាមនុស្សថ្លង់ ជាមនុស្សមានបញ្ហាស្មារតី ឬក៏ជនជាប់ចោទគ្មានសមត្ថភាពក្នុងការរកមេធាវីដោយខ្លួនឯងបាន។

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥(ប្រាំ) ថ្ងៃមុនការសួរចម្លើយ។ ការសួរចម្លើយជនត្រូវចោទអាចធ្វើនៅចំពោះមុខមេធាវីរបស់ជនត្រូវចោទបាន។ ប៉ុន្តែប្រសិនបើមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និង ម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវីបាន។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុផ្សេងពីកំណត់ហេតុសួរចម្លើយ។ ក្នុងករណីបន្ទាន់ ការសួរចម្លើយអាចធ្វើដោយមិនបាច់កោះហៅមេធាវីបាន ដូចជាមានគ្រោះថ្នាក់បណ្តាលអោយស្លាប់ ឬមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាងបន្ថែម។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[21]

[20] មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[21] មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងនីតិវិធីព្រហ្មទណ្ឌ លោកគ្រូ រុន ពណ្ណារិទ្ធិ។

នីតិវិធីសួរចម្លើយ ក្នុងករណីដែលមានវត្តមានមេធាវីជនត្រូវចោទ និងព្រះរាជអាជ្ញាចូលរួម គ្រប់សំនួរដែលពួកគាត់ចង់សួរ គឺត្រូវតែមានការអនុញ្ញាតពីចៅក្រមជាមុនសិន។[22] ការសួរចម្លើយ ប្រសិនរយៈពេល ៤ (បួន) ខែ បានកន្លងផុតទៅចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនដំបូងដោយចៅក្រមស៊ើបសួរមិនបានកោះហៅជនត្រូវចោទមកបង្ហាញខ្លួន និងសួរចម្លើយទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយប្រសិនបើជនត្រូវចោទបានស្នើសុំ។ បន្ទាប់ពីជនត្រូវចោទបានស្នើសុំហើយក្នុងរយៈពេល ១(ខែ) ចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទទេ នោះជនត្រូវចោទមានសិទ្ធិប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។[23]

ក្រោយពីការសួរចម្លើយត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខានៅគ្រប់ទំព័រនៃកំណត់ហេតុសួរចម្លើយ ចំណែកឯជនត្រូវចោទត្រូវផ្តិតមេដៃទទួលស្គាល់ចម្លើយខ្លួន និងអានចម្លើយរបស់ខ្លួន ក្នុងករណីជនត្រូវចោទមិនចេះអក្សរក្រឡាបញ្ជីត្រូវអានចម្លើយឲ្យជនត្រូវចោទស្តាប់។ កំណត់ហេតុមិនត្រូវទុកឲ្យមានចន្លោះបន្ទាត់ទំនេរទេ រាល់ការឆ្កូត លុប ឬយោង ត្រូវតែបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។[24]

### ២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីអោយចៅក្រមស៊ើបសួរ សួរបញ្ជាក់អំពីរឿងហេតុដែលបានកើតឡើង និងស្វែងរកតម្រុយបន្ថែមទៀតទាក់ទងនិងរឿងក្តីនេះ។ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវី ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ ថ្ងៃមុនការស្តាប់ចម្លើយ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនបានចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានមេធាវី។ និទ្ទេសស្តីពីអវត្តមានត្រូវចុះក្នុងកំណត់ហេតុស្តាប់ចម្លើយ។

[22] មាត្រា ១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[23] មាត្រា ១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[24] មាត្រា ២៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ក្នុងករណីពិសេសចៅក្រមស៊ើបសួរ អាចសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី បោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ ត្រូវបានបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីភាពភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[25] ក្នុងករណីដែលមានវត្តមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាចូលរួមគ្រប់សំនួរដែលពួកគាត់ចង់សួរ គឺត្រូវតែមានការអនុញ្ញាតពីចៅក្រមជាមុនសិន។[26]

**៣. ការស្តាប់ចម្លើយសាក្សី**

សាក្សី គឺជាបុគ្គលដែលបានឃើញបានដឹងនូវហេតុការណ៍ ឬជាបុគ្គលដែលមានវត្តមាននៅកន្លែងកើតហេតុ និងអាចផ្តល់ពត៌មានដែលជាប្រយោជន៍ ក្នុងការសម្តែងឲ្យឃើញការពិត។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាបុគ្គលរូបណាមានសារៈសំខាន់ គាត់មានអំណាចកោះហៅបុគ្គលនោះក្នុងឋានៈជាសាក្សី។ ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈបង្ខំសាក្សីឲ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឲ្យចូលមកបង្ហាញខ្លួន បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សីហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[27] ក្នុងករណីសាក្សីឈឺ ឬ មិនអាចធ្វើដំណើរបានចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់លំនៅឋាន ឬ ទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលបានចម្លើយ។[28]

សាក្សីត្រូវឆ្លើយទៅតាមហេតុការណ៍ដែលខ្លួនបានដឹង ឬបានឃើញទៅតាមការពិត ហើយសាក្សីមិនត្រូវឆ្លើយតាមតែចិត្តចង់ ឬតាមតែគំនិតរបស់ខ្លួនដែលខុសពីការពិតទេ។

[25] មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

[26] មាត្រា ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[27] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[28] មាត្រា ១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

មួយវិញទៀត សាក្សីមិនត្រូវឆ្លើយតាមការគំរាមកំហែង ការបង្ខិតបង្ខំ ឬឆ្លើយតាមការបង្គាប់របស់បុគ្គលណាម្នាក់ឡើយ។ ដូច្នេះហើយចំពោះសាក្សីមុននឹងឆ្លើយទៅនឹងសំនួរ សាក្សីម្នាក់ៗត្រូវស្បថស្របតាមជំនឿសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។[29] ប៉ុន្តែមានសាក្សីមួយចំនួនដែលអនុញ្ញាតឲ្យរួចពីសម្បថរួមមាន៖

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ។
- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ។
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ។
- កុមារអាយុតិចជាង ១៤ ឆ្នាំ។[30]

គួរកត់សំគាល់ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ហើយចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីបានផងដែរ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយ ដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តិបទល្មើសនោះទេ។ ក្នុងករណីនេះចៅក្រមត្រូវយកនីតិវិធីនៃមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។[31] ចំពោះការដាក់ឲ្យស្ថិតក្រោមការពិនិត្យនេះ គឺចៅក្រមស៊ើបសួរអាចដាក់បុគ្គលដែលមានពិរុទ្ធិនោះក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត។[32]

---

[29] មាត្រា ១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[30] មាត្រា ១៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[31] មាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[32] មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

## ផ្នែកទី២. ការស្រាវជ្រាវទាក់ទងនឹងភស្តុតាង

### ១. ការចុះទៅពិនិត្យដល់កន្លែងកើតហេតុ

ចៅក្រមស៊ើបសួរ គឺអាចចុះទៅទីកន្លែងកើតហេតុ ជាមួយក្រឡាបញ្ជីរបស់ខ្លួននៅវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូងរបស់ខ្លួន ដើម្បីបំពេញកិច្ចសើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ការពិនិត្យសម្ភារៈ ភស្តុតាង ការឆែកឆេរ និងការចាប់យកភស្តុតាង។ ចំពោះការចុះទៅពិនិត្យនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ព្រោះក្នុងករណីនេះព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរដែរ។ បន្ទាប់ពីបានចុះទៅពិនិត្យហើយ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីប្រតិបត្តិការរបស់ខ្លួន។[33]

### ២. ការឆែកឆេរ និងការចាប់យកភស្តុតាង

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ប៉ុន្តែការឆែកឆេរនេះត្រូវតែគោរពទៅតាមវិធានដែលច្បាប់បានកំណត់។ នៅក្នុងការឆែកឆេរ ចៅក្រមស៊ើបសួរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ដែលខ្លួនតាំង។ សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ជាពិសេសចៅក្រមស៊ើបសួរ មិនអាចឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។ ប៉ុន្តែយ៉ាងណាមិញដើម្បីបង្ការទប់ស្កាត់នូវបទល្មើស និងរក្សានូវភស្តុតាង ក៏ដូចជារក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៅក្នុងសង្គម ច្បាប់ក៏បានអនុញ្ញាតអោយចៅក្រមស៊ើបសួរធ្វើការឆែកឆេរ ដោយពុំចាំបាច់គោរពទៅតាមវិធានច្បាប់ដែលបានកំណត់ខាងលើក្នុងករណី៖

- ឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន
- ឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន។

ចំពោះការឆែកឆេរនៅក្នុងការិយាល័យមេធាវី គឺត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ហើយការឆែកឆែរនេះត្រូវមានវត្តមានចៅក្រម

[33] មាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ស៊ើបសួរ។ នៅពេលឆែកឆេរ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ២ (ពីរ) នាក់។[34]

ក្រៅពីការឆែកឆេរ ចៅក្រមស៊ើបសួរក៏អាចចាប់យកវត្ថុតាងដើម្បីធ្វើជាភស្តុតាងហើយចំពោះវត្ថុតាងនោះត្រូវតែបិទស្លាកបោះត្រា ហើយត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យករួមទាំងបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក ក្រោយពីបានបង្ហាញវត្ថុចាប់យកដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សី ២ (ពីរ) នាក់រួចមក។[35]

### ៣. កោសលវិច័យ

ក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី[36] ដោយចេញដីការចាត់តាំងអ្នកជំនាញ បញ្ជាក់ពីបេសកកម្មរបស់អ្នកជំនាញ និងរយៈពេលត្រូវបំពេញបេសកកម្មនេះ។ ចំពោះការប្រគល់វត្ថុចាប់យកជូនអ្នកជំនាញ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុចាប់យក។[37] អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួនក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ លើសពីនេះទៅទៀតក្នុងកាលៈទេសៈចំបាច់ណាមួយ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីការសម្រេចឲ្យអ្នកជំនាញធ្វើការពន្យារពេលបាន។[38] ចៅក្រមស៊ើបសួរចាត់តាំងអ្នកជំនាញដែលមានក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ដែលរៀបចំឡើងដោយមន្ត្រីក្រសួងយុត្តិធម៌ ហើយអ្នកជំនាញត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ។[39] លើសពីនេះទៀតចៅក្រមស៊ើបសួរក៏អាចចាត់តាំងអ្នកជំនាញដែលមិនមានឈ្មោះក្នុងបញ្ជីអ្នកជំនាញបានដែរ តាមដីការសំអាងហេតុជាពិសេស តែត្រូវឲ្យអ្នកជំនាញនោះស្បថសិនមុននឹងបំពេញបេសកកម្ម។[40]

[34] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[35] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[36] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[37] មាត្រា ១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[38] មាត្រា ១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[39] មាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[40] មាត្រា ១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ដើម្បីបំពេញបេសកកម្មខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ក្រៅពីជនត្រូវចោទហើយបុគ្គលនោះមិនចាំបាច់ស្បថទេ។ ប៉ុន្តែប្រសិនបើយល់ឃើញថាចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឲ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួនបានចំពោះមុខមេធាវី ប៉ុន្តែបើជាការពិនិត្យវេជ្ជសាស្រ្ត ឬចិត្តសាស្រ្ត ត្រូវធ្វើដោយគ្មានវត្តមានមេធាវី។[41] កាលណាបេសកកម្មកោសលវិច័យបានបញ្ចប់ អ្នកជំនាញត្រូវធ្វើរបាយការណ៍ដែលនៅក្នុងនោះ ត្រូវពណ៌នាយ៉ាងច្បាស់លាស់អំពីបេសកកម្មរបស់ខ្លួនហើយនឹងធ្វើសេក្តីសន្និដ្ឋាន។ អ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួន នូវបេសកកម្មដែលពណ៌នា ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។[42]

ចៅក្រមស៊ើបសួរ ក្រោយពីទទួលបានរបាយការណ៍កោសលវិច័យ ត្រូវជូនពត៌មានដល់ព្រះរាជអាជ្ញា ហើយកោះហៅជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃការកោសលវិច័យនោះ។ ក្រោយពីបានដឹងពីសេចក្តីសន្ទដ្ឋាននៃកោសលវិច័យរួចហើយព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹបរដ្ឋប្បវេណី អាចដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ តែរយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃ។ ប្រសិនបើមានពាក្យយ៉ាងដូច្នេះហើយចៅក្រមស៊ើបសួរពុំព្រមធ្វើតាមពាក្យសុំទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីការមានសំអាងហេតុក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បើសិនជាពាក្យសុំចេញដោយព្រះរាជអាជ្ញា និងរយៈពេល ១ (មួយ) ខែ បើសិនជាពាក្យសុំចេញដោយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។[43]ចំពោះសោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ តែបើការស្នើសុំឲ្យធ្វើដោយចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្រ្តីនគរបាលយុត្តិធម៌ សោហ៊ុយជាបន្ទុករបស់រដ្ឋ។[44]

[41] មាត្រា ១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[42] មាត្រា ១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងនីតិវិធីព្រហ្មទណ្ឌ លោកគ្រូ រុន ពណ្ណារិទ្ធិ។
[43] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[44] មាត្រា ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ៤. ការស្ដាប់ទូរស័ព្ទ

ការស្តាប់ទូរស័ព្ទ គឺជាវិធានការមួយដែលប៉ះពាល់ដល់សិទ្ធិបុគ្គលឯកជន ដែលធានាដោយរដ្ឋធម្មនុញ្ញទាក់ទិននឹងការរក្សាការសម្ងាត់នៃការឆ្លងឆ្លើយគ្នា។ ហេតុនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឲ្យតែចៅក្រមស៊ើបសួរប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចបង្គាប់ឲ្យស្តាប់ទូរស័ព្ទបាន។

ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិឲ្យចៅក្រមស៊ើបសួរក្នុងការបង្គាប់ឲ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លងឆ្លើយគ្នា តាមមធ្យោបាយទូរគមនាគមន៍ផ្សេងៗទៀតដូចជា សារតាមទូរសារតាមអ៊ិនធឺណិត។ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចដើម្បីឲ្យអង្គភាពសាធារណៈ ឬ មន្ត្រីរាជការដែលជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថតដោយបញ្ជាក់ពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ថត និងរយៈពេលនៃបេសកកម្មនេះផង។ ក្រោយពេលបំពេញបេសកកម្មនេះរួចហើយអង្គភាពសាធារណៈ ឬមន្ត្រីរាជការត្រូវចម្លងជាលាយល័ក្ខណ៍អក្សរនូវសម្លេងដែលបានថត ហើយប្រគល់ឯកសារ និងសម្លេងថតបានឲ្យទៅចៅក្រមស៊ើបសួរ។ ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតសម្លេងនោះបានគ្រប់ពេលវេលា ហើយចំពោះការចូលទៅកាន់ទីកន្លែងទាំងនេះ មិនអាចហាមឃាត់ដល់ចៅក្រមស៊ើបសួរ ដោយសំអាងលើមូលហេតុអ្វីបានទេទោះបីជាទីកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចនេះតាមដីកាចាត់ឲ្យស៊ើបសួរជំនួសបានដែរ។[45]

## ផ្នែកទី៣. ការប្រកាសសេចក្តីសម្រេចអំពីការឃុំខ្លួនជនត្រូវចោទ

### ១. ការឃុំខ្លួនតាមការស្នើសុំរបស់អយ្យការ

ចំពោះការស្នើសុំឃុំខ្លួនជនត្រូវចោទដោយអយ្យការ គឺនៅពេលដែលព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមកចៅក្រមស៊ើបសួរ ហើយនៅក្នុងដីកានោះព្រះរាជអាជ្ញាអាចស្នើសុំឲ្យមានការឃុំខ្លួនជនត្រូវចោទ ឬស្នើសុំឲ្យដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ បន្ទាប់ពីចៅក្រមស៊ើបសួរបានទទួលនូវការស្នើសុំឲ្យឃុំខ្លួនជនត្រូវចោទពីព្រះរាអាជ្ញា ហើយប្រសិនបើចៅក្រមស៊ើបសួរ ក៏យល់ឃើញដូច

[45] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងនីតិវិធីព្រហ្មទណ្ឌ លោកគ្រូ រុន ពណ្ណារិទ្ធិ។

ព្រះរាជអាជ្ញាដែរ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន និងដីកាបង្គាប់ឲ្យឃុំខ្លួន។ ក្នុងករណីដែលចៅក្រមស៊ើបសួរ ចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវភ្ជាប់មកនូវជាមួយសំអាងហេតុ និងត្រូវជូនដំណឹងដល់ជនត្រូវចោទ។ ចំពោះការសំអាងហេតុផលនេះ គឺចង់សំដៅទៅលើមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ដូចដែលមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ហើយចំនុចនេះក៏បានបកស្រាយដែលនៅក្នុង **ផ្នែកទី២. នីតិវិធីពន្យារពេល និងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រង់ចំនុចទី១.១ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន។**[46]

**២. ការឃុំខ្លួនតាមគំនិតផ្ទាល់របស់ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចថានឹងឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ដោយគំនិតផ្ទាល់របស់ខ្លួនបានដោយមិនចាំបាច់ខ្វល់ថាមាន ឬគ្មានការស្នើសុំពីព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឡើយ ឲ្យតែចៅក្រមយល់ឃើញថាត្រូវឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន។ ចំពោះដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរត្រូវតែមានសំអាងហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ដូចដែលមានចែងក្នុងមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។[47]

ចៅក្រមស៊ើបសួរមានសិទ្ធិសម្រេច មិនឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ប្រសិនមានការស្នើសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ហើយក្នុងករណីដែលចៅក្រមស៊ើបសួរមិនយល់ស្រមតាមគំនិតរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចសម្រេចមិនឃុំខ្លួនជនត្រូវចោទ តាមដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន។ ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរអាចសម្រេចដោយពុំចាំបាច់មានសំអាងហេតុឡើយ ម៉្យាងទៀតដីកានេះត្រូវតែចេញក្នុងរយៈពេល ៥ (ប្រាំថ្ងៃ) គិតប្រាប់ពីថ្ងៃដែលទទួលបានបណ្ដឹង តាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញា

[46] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[47] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

អាចធ្វើពាក្យបណ្តឹងទៅសភាស៊ើបសួរពីបញ្ហានេះបាន ដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។[48]

**៣. ការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ**

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ ចំពោះដីកាសម្រេចដាក់ខ្លួនឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ប្រសិនបើមានការស្នើសុំ ឲ្យដាក់ខ្លួនជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរមិនព្រមសម្រេចតាមការស្នើសុំរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមស៊ើបសួរត្រូវចេញដីការបដិសេធការស្នើសុំនោះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរបានដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួស។ នៅក្នុងចំនុចនេះដែល ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយឲ្យបានស៊ីជម្រៅ និងក្បោះក្បាយនៅក្នុង **ផ្នែកទី២. នីតិវិធីពន្យារពេល និងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រង់ចំនុចទី២. ការត្រួតពិនិត្យតាមផ្លូវតុលាការ**។[49]

**៤. ទណ្ឌកម្មនៃការគេចវេះពីកាតព្វកិច្ចដែលដាក់ចេញដោយតុលាការ**

ជនត្រូវចោទ បន្ទាប់ពីបានទទួលដំណឹងពីចៅក្រមស៊ើបសួរនូវដីកាបង្គាប់ឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការហើយ ប្រសិនបើជនត្រូវចោទនោះមានចេតនាគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ គឺវាមានលក្ខណៈខុសគ្នាពីមាត្រា ២០៤ (ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន) ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិប្បរមា ដែល

[48] មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[49] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

មានចែងដោយមាត្រា ២០៨ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១០ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍) មាត្រា ២១៣ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងមាត្រា ២១៤ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ កាលណាចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមធ្យោបាយការពារកូនក្ដីរបស់ខ្លួន។

ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទ តាមដីកាដែលមានសំអាងហេតុ ហើយការឃុំខ្លួនបណ្ដោះអាសន្នដែលសម្រេចតាមមូលហេតុនៃ ការគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការនេះមិនអាចឲ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន។[50]

**ផ្នែកទី៤. នីតិវិធីចាត់អោយស៊ើបជំនួស**

**១. អត្ថន័យ**

ការចាត់អោយស៊ើបជំនួស គឺជាការប្រគល់សិទ្ធិឲ្យទៅអ្នកផ្សេងដែលមានសមត្ថកិច្ចស៊ើបសួរជំនួស ក្នុងករណីដែលចៅក្រមស៊ើបសួរអាចជួបប្រទះនឹងឧបសគ្គផ្សេងៗ ដែលជាហេតុនាំឲ្យចៅក្រមស៊ើបសួរពុំអាចបំពេញភារកិច្ចដោយខ្លួនឯងបាន តាមដីកាចាត់ឲ្យស៊ើបសួរជំនួស។ ដីកាចាត់ឲ្យស៊ើបជំនួស គឺជាដីកាដែលចៅក្រមស៊ើបសួរចេញទៅឲ្យមន្ត្រីដែលមានសមត្ថកិច្ចដើម្បីស៊ើបសួរជំនួសខ្លួន ហើយដីកានោះត្រូវបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកានេះចៅក្រមស៊ើបសួរត្រូវតែណែនាំ អោយបានច្បាស់លាស់នូវអ្វីដែលខ្លួនចង់អោយស៊ើបសួរជំនួស មិនអាចមានលក្ខណៈជាទូទៅបានទេ។[51]

[50] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[51] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

**២. បុគ្គលដែលមានសមត្ថកិច្ចក្នុងការស៊ើបជំនួស**

ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឲ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរបាន។[52] ក្នុងករណីដែលដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានចេញឲ្យដល់ចៅក្រមម្នាក់ទៀត ចៅក្រមរូបនោះអាចប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរបាន[53]។ មួយវិញទៀត ក្នុងករណីដែលដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[54]

**៣. ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស**

ចំពោះការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធមម៌ត្រូវបំពេញកិច្ចដែលមានចែងក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស នៅក្នុងដែលសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែមានបញ្ញត្តិនៃមាត្រា ៦៨ ( ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។[55] ការបំពេញកិច្ចនេះមន្ត្រីនគរបាលយុត្តិធម៌ គឺស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរអំពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យនោះ។[56]

មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការស៊ើបសួរជំនួសទាក់ទិននឹង៖

- ការស្តាប់ចម្លើយជនត្រូវចោទ
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។[57]

[52] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[53] មាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[54] មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[55] មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[56] មាត្រា ១៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[57] មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការកោះហៅ និងស្តាប់ចម្លើយសាក្សីបានប៉ុន្តែមុននឹងឲ្យឆ្លើយសំនួរមន្ត្រីនគរបាលយុត្តិធម៌ត្រូវអោយសាក្សីស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតជាមុនសិន។ ក្នុងករណីដែលសាក្សីរឹងទទឹងមិនព្រមចូលបង្ហាញខ្លួនតាមការកោះហៅមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ដើម្បីអោយចៅក្រមស៊ើបសួរចេញបញ្ជាឲ្យចូលបង្ហាញខ្លួន។ បញ្ជាឲ្យចូលបង្ហាញខ្លួន គឺអនុញ្ញាតឲ្យមន្ត្រីនគរបាយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈក្នុងការបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខ។ ចំពោះបញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[58] ប្រសិនបើ មានការឃាត់ខ្លួនក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបជំនួស អំណាចដែលប្រគល់ឲ្យព្រះរាជអាជ្ញាត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ។[59]

## ផ្នែកទី៥. ការប្រគល់វត្ថុចាប់យកឲ្យម្ចាស់វិញ

ការប្រគល់វត្ថុចាប់យកឲ្យម្ចាស់វិញ គឺជាការប្រគល់វត្ថុដែលចៅក្រមស៊ើបសួរបានចាប់យក និងដកហូតវត្ថុដែលពាក់ព័ន្ធនឹងបទល្មើស ហើយយកមកដើម្បីទុកជាភស្តុតាងក្នុងការស្វែងរកតម្រុយបន្ថែមពីមន្ត្រីនគរបាលយុត្តិធម៌។ ចំពោះវត្ថុដែលចាប់យកនេះចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការប្រគល់ឲ្យ ឬបដិសេធមិនប្រគល់ឲ្យទៅម្ចាស់វិញ។

### ១. នីតិវិធីប្រគល់វត្ថុចាប់យក

ចំពោះនីតិវិធីនេះ ចៅក្រមស៊ើបសួរមានអំណាចក្នុងការប្រគល់វត្ថុចាប់យកឲ្យម្ចាស់វិញតាមឆន្ទានុសិទ្ធិរបស់គាត់ ដោយចេញដីកាសម្រេចដែលមានសំអាងហេតុ បន្ទាប់ពីមានយោបល់ពីព្រះរាជអាជ្ញា ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដោយមានការស្នើសុំពីគូភាគី ឬពីគ្រប់បុគ្គលទាំងអស់ដែលមានប្រយោជន៍លើវត្ថុដែលចាប់យក។[60]

---

[58] មាត្រា ១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[59] មាត្រា ១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[60] មាត្រា ១៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ២. លក្ខខណ្ឌនៃការប្រគល់វត្ថុចាប់យក

ចំពោះលក្ខខណ្ឌនេះ គឺចៅក្រមស៊ើបសួរយល់ឃើញថា ការប្រគល់វត្ថុចាប់យកទៅឲ្យម្ចាស់វិញនោះមិនធ្វើឲ្យមានភាពរាំងស្ទះ ឬបង្កជាឧបសគ្គដល់ការស្វែងរកឲ្យឃើញការពិត និងមិនប៉ះពាល់ដល់នីតិវិធីស៊ើបសួរ ហើយព្រះរាជអាជ្ញា ក៏យល់ឃើញថាវត្ថុនោះគួរតែប្រគល់ឲ្យម្ចាស់ ឬអ្នកមានប្រយោជន៍លើវត្ថុចាប់យកនោះវិញ។[61]

### ៣. ការសម្រេចមិនប្រគល់វត្ថុចាប់យក

ចៅក្រមស៊ើបសួរ គឺមានសិទ្ធិបដិសេធមិនប្រគល់វត្ថុចាប់យកឲ្យម្ចាស់វិញ បើចៅក្រមស៊ើបសួរយល់ឃើញថា ការប្រគល់វត្ថុចាប់យកនោះនាំឲ្យមានភាពរាំងស្ទះ ឬបង្កជាឧបសគ្គដល់ការស្វែងរកការពិត និងធ្វើអោយបាត់បង់នូវភស្តុតាង ឬតម្រុយផ្សេងៗនៅក្នុងនីតិវិធីស៊ើបសួរ។ ម្យ៉ាងវិញទៀតវត្ថុនោះជាវត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ហើយវត្ថុដែលការកាន់កាប់មិនស្របច្បាប់ គឺមិនអាចប្រគល់សងទៅឲ្យម្ចាស់វិញទេ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរដ្ឋ។[62]

### ៤. សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

កាលណាបើចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាសម្រេចបដិសេធមិនប្រគល់វត្ថុចាប់យកឲ្យម្ចាស់វិញនោះ ក្នុងករណីនេះតាមក្រមនីតិវិធីព្រហ្មទណ្ឌបានបើកសិទ្ធិឲ្យម្ចាស់ និងគ្រប់បុគ្គលដែលមានប្រយោជន៍ អាចមានសិទ្ធិប្តឹងទៅឧទ្ធរណ៍ចំពោះដីការសម្រេចរបស់ចៅក្រមស៊ើបសួរ។ ដូច្នេះ ម្ចាស់វត្ថុ ឬគ្រប់បុគ្គលដែលមានប្រយោជន៍លើវត្ថុចាប់យក អាចប្តឹងទៅឧទ្ធរណ៍បានចំពោះដីកាសម្រេចបដិសេធមិនប្រគល់វត្ថុចាប់យករបស់ចៅក្រមស៊ើបសួរ។ ចំពោះរយៈពេលនៃការប្តឹងទៅឧទ្ធរណ៍មានរយៈពេល ៥(ប្រាំ) ថ្ងៃ គិតចាប់ពីការជូនដំណឹងពីដីកា។[63]

---

[61] មាត្រា ១៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងដីកាសម្រេចប្រគល់វត្ថុចាប់យកឲ្យម្ចាស់ដើមវិញក្នុងឧបសម្ព័ន្ធ។

[62] មាត្រា ១៦១ កថាខណ្ឌទី២-៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[63] មាត្រា ២៦៩, ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

# ជំពូកទី៣ វិធានការនិរន្តរាយ

## ផ្នែកទី១. យន្តការបង្ខារ និងទប់ស្កាត់បទល្មើស

### ១. ដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។[64] ដីកានេះត្រូវឲ្យដំណឹងដល់ជនពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។[65]

ដីកាបង្គាប់ឲ្យចូលខ្លួន ចៅក្រមស៊ើបសួរតម្រូវឲ្យចុះនិទ្ទេសដែលរួមមានដូចជាអត្តសញ្ញាណនៃបុគ្គលដែលជាប់ពាក់ព័ន្ធ បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ ពេលវេលា ទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ និង ឈ្មោះ ឋានៈរបស់ខ្លួនដែលចេញដីកា។[66]

សម្រាប់ការកោះហៅជនត្រូវចោទ ត្រូវធ្វើទៅតាមអាសយដ្ឋានចុងក្រោយបង្អស់ដែលបានប្រកាសដូចដែលមានចែងនៅមាត្រា ១៨៣ (ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[67] ករណីជនត្រូវចោទ ដែលបានឃុំខ្លួនត្រូវកោះហៅតាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[68]

### ២. ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញតែទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមាន តម្រុយពិរុទ្ធភាពប៉ុណ្ណោះ។[69] ក្រៅពីលក្ខខណ្ឌនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់នូវលក្ខខណ្ឌណាផ្សេងទៀត ដើម្បីឲ្យចៅក្រមស៊ើបសួរអាចចេញ

[64] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[65] មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[66] មាត្រា ១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[67] មាត្រា ២៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[68] មាត្រា ២៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[69] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ដីកាបង្គាប់ឲ្យនាំខ្លួនទេ។ ហេតុនេះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនភ្លាម ដោយពុំចាំបាច់ចេញដីកាបង្គាប់ឲ្យចូលខ្លួនជាមុនទេ ក្នុងករណីដែលចៅក្រមយល់ឃើញថាជាការចាំបាច់។

ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីមានដីកាបង្គាប់ឲ្យនាំខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធបាន ដោយពុំចាំបាច់មានការអនុញ្ញាតឲ្យឆែកឆេរទេ ដែលការហាមឃាត់ការចូលលំនៅឋានមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។[70]

នៅពេលដែលជនត្រូវបានចាប់ខ្លួន និងនាំខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ហើយ ជននេះត្រូវតែយកទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ យ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់។ បើពុំដូច្នោះជននេះត្រូវដោះលែងឲ្យមានសេរីភាពវិញ។[71] ក្នុងករណីនេះ ថិរវេលានៃការឃុំខ្លួនតាមដីកាបង្គាប់ឲ្យនាំខ្លួន នឹងត្រូវរាប់បញ្ចូលទៅក្នុងថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន។[72]

**៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ។[73]

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាង ក្រោម៖

- បង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព
- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬ មជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

[70] មាត្រា ១៩២ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[71] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[72] មាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[73] មាត្រា ១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជណាកម្ពុជា[74]
- ចៅក្រមស៊ើបសួរបានទទួលយោបល់ព្រះរាជអាជ្ញាលើបញ្ហាចាប់ខ្លួននេះ (មុននឹងចេញដីកា បង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរចេញដីកាបញ្ជូនឲ្យឆ្លើយ ដើម្បីឲ្យព្រះរាជអាជ្ញាផ្តល់យោបល់ពីការបង្គាប់ឲ្យចាប់ខ្លួន។[75] ប៉ុន្តែយោលបល់របស់ព្រះរាជអាជ្ញាពុំមានអានុភាពចង ចៅក្រមស៊ើបសួរឲ្យធ្វើតាមនោះទេ)។

ព្រះរាជអាជ្ញា គឺជាអ្នកធានារ៉ាប់រងការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។[76] មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌អាចចូលក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធបាន ដោយពុំចាំបាច់មានការអនុញ្ញាតឲ្យឆែកឆេរនោះទេ ហើយមិនអាចចូលបានមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ឡើយ។ ខុសប្លែកពីដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌បាន ដោយប្រើយន្តការនានា ដែលមានប្រសិទ្ធភាព។[77]ជនពាក់ព័ន្ធត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសក្នុងរយៈពេលយ៉ាងខ្លីបំផុត។[78] ប្រសិនបើជននេះពុំអាចត្រូវគេនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសនៅក្នុងថ្ងៃបន្ទាប់ពីការចាប់ខ្លួន ជននេះត្រូវបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួន ស្តាប់ចម្លើយ ដោយកំណត់ហេតុនៃការស្តាប់ចម្លើយត្រូវបញ្ជូនខ្លួនទៅចៅក្រមស៊ើបសួរ។ ការឃុំខ្លួនដោយសារការអនុវត្តន៍ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន។[79]

[74] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[75] មាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[76] មាត្រា ១៩៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[77] មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[78] មាត្រា ២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[79] មាត្រា ២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

**៤. ដីកាបង្គាប់ឲ្យឃុំខ្លួន**

ដីកាបង្គាប់ឲ្យឃុំខ្លួន គឺជាបញ្ជារដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទ ហើយចៅក្រមស៊ើបសួរ អាចនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន ក្នុងលក្ខខណ្ឌជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ បានន័យថា ចាប់ពីចៅក្រមស៊ើបសួរចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នរួចមក គាត់ដាច់ខាតត្រូវតែចេញដីកាបង្គាប់ឲ្យឃុំខ្លួន ព្រោះថាដីកាបង្គាប់ឲ្យឃុំខ្លួនជាបញ្ជារឲ្យប្រធានពន្ធនាគារទទួលយកជនត្រូវចោទ និងឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន។ ហើយប្រធានពន្ធនាគារត្រូវទទួលយកជនត្រូវចោទ និងធ្វើការឃុំខ្លួនជននោះដូចមានបញ្ជាក់អត្តសញ្ញាណនៅក្នុងដីកាបង្គាប់ឲ្យឃុំខ្លួន រហូតទាល់តែបានទទួលការឲ្យដំណឹងពីការដោះលែងឲ្យមានសេរីភាពវិញ ហេតុនេះប្រសិនបើមិនមានដីកាបង្គាប់ឲ្យឃុំខ្លួនទេ ប្រធានពន្ធនាគារក៏មិនអាចទទួលឃុំខ្លួនជនត្រូវចោទនោះបានឡើយ។

**ផ្នែកទី២. នីតិវិធីពន្យារ និងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

**១. ការឃុំខ្លួនបណ្តោះអាសន្ន**

**១.១. គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន**

ក្រោយពីជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទល្មើសណាមួយហើយ ចៅក្រមស៊ើបសួរត្រូវពិចារណា ទៅលើបញ្ហាឃុំខ្លួនជននេះជាបណ្តោះអាសន្ន ឬអត់។ យ៉ាងណាមិញការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ត្រូវតែជាករណីពិសេស។[80]

**<u>មិនឃុំខ្លួនជនត្រូវចោទ៖</u>** ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរពុំចាំបាច់ចេញដីកាសម្រេចអ្វីនោះទេ គឺចៅក្រមស៊ើបសួរអនុញ្ញាតឲ្យជនត្រូវចោទត្រឡប់ទៅវិញ ក្រោយពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ឬក្រោយពីការសួរចម្លើយរួចហើយ។ ប៉ុន្តែបើសិនជាព្រះរាជអាជ្ញាបានស្នើសុំឲ្យចៅក្រមស៊ើបសួរឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន (ការស្នើសុំដោយផ្ទាល់មាត់នាពេលដែលមានការពិភាក្សាដេញដោលពីបញ្ហាឃុំខ្លួន ឬ ធ្វើសេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរ) ហើយ

[80] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ចៅក្រមស៊ើបសួរយល់ឃើញថាពុំត្រូវឃុំខ្លួនជនត្រូវចោទទេនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដោយពុំចាំបាច់មានសំអាងហេតុទេ។[81] ដីកានេះត្រូវឲ្យដល់ភ្លាមដល់ព្រះរាជអាជ្ញា ហើយប្រសិនបើ ចៅក្រមស៊ើបសួរពុំបានចេញដីកាសម្រេចនេះនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នោះព្រះរាជអាជ្ញាអាចប្ដឹងផ្ទាល់ទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។[82]

**ឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន៖** ប្រសិនបើចៅក្រមស៊ើបសួរយល់ថា ត្រូវឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវចេញដីកាចំនួនពីរគឺ: **ដីកាសម្រេចឲ្យឃុំខ្លួនជា បណ្ដោះអាសន្ន** និង **ដីកាបង្គាប់ឲ្យឃុំខ្លួន**។ ដីកាសម្រេចជាសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលអាចជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍បាន។ ចំណែកឯដីកាបង្គាប់ឲ្យឃុំខ្លួនវិញគ្រាន់តែជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំជនត្រូវចោទប៉ុណ្ណោះ។ ហេតុនេះដីកាបង្គាប់ឲ្យឃុំខ្លួនពុំអាចជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍បានទេ។

### ១.២. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន គឺអាចប្រព្រឹត្តិទៅបានលុះត្រាតែគោរពទៅតាមលក្ខខណ្ឌដូចដែល មានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដោយជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ឆ្នាំ។[83] ហេតុនេះប្រសិនបើ ជនត្រូវចោទជាប់ចោទពីបទល្មើសប្រើប្រាស់គ្រឿងញៀនដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ) ខែ ជនត្រូវចោទនេះពុំអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នដោយចៅក្រមស៊ើបសួរឡើយ។[84]

### ១.៣. មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

មូលហេតុនៃការស៊ើបសួបណ្ដោះអាសន្នមាន ៦គឺ:

(១) ដើម្បីបញ្ចប់បទល្មើស ឬបង្កាបទល្មើសកុំឲ្យកើតមានជាថ្មី

[81] មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[82] មាត្រា ២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[83] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[84] មាត្រា ៩៨ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

(២) ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

(៣) ដើម្បីរក្សាភស្តុតាង និងតម្រុយជាសម្ភារៈ

(៤) ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

(៥) ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ

(៦) ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[85]

នៅក្នុងកិច្ចពិភាក្សាដេញដោលពីបញ្ហាឃុំខ្លួន ចៅក្រមស៊ើបសួរត្រូវឲ្យក្រឡាបញ្ជីធ្វើការ កំណត់ហេតុមួយឈ្មោះថា **កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ** ក្នុងគោលដៅឲ្យ ព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានពីបញ្ហាឃុំខ្លួនជនត្រូវចោទ និងមេធាវីការពារជនត្រូវចោទផ្តល់ការសម្គាល់ ឬសេចក្តីសន្និដ្ឋានពីបញ្ហាឃុំខ្លួនដល់ចៅក្រមស៊ើបសួរ ដែលជាមូលដ្ឋានឲ្យចៅក្រមស៊ើបសួរសម្រេចថាគួរឃុំខ្លួន ឬមិនឃុំខ្លួនជនត្រូវចោទ[86]។

### ១.៤. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថាឃុំខ្លួនជនត្រូវចោទជាពណ្តោះអាសន្ន ការឃុំខ្លួន ជាបណ្តោះអាសន្ននេះត្រូវស្ថិតក្នុងថិរវេលាដែលកំណត់ដោយច្បាប់។ ថិរវេលានេះ ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទឃុំខ្លួន៖

**<u>ប្រសិនបើជាប់ចោទពីបទឧក្រិដ្ឋ៖</u>** ករណីជនត្រូវចោទជានីតិជន រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នគឺ ៦ (ប្រាំមួយ) ខែ ហើយអាចមានការពន្យារពេលបានចំនួន ២ដងបន្តទៀតតាមរយៈដីកាដោយមានសំអាងហេតុ។[87] ករណីចៅក្រមស៊ើបសួរ បានសម្រេចពន្យារពេលឃុំខ្លួនរបស់ជនជាប់ចោទជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឲ្យដំណឹងដល់ជន

[85] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[86] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[87] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ត្រូវចោទ នឹងទទួលការកត់សំគាល់របស់ជននេះ។ នៅពេលដែលជនត្រូវចោទមានមេធាវីអម នោះមេធាវីត្រូវតែបង្ហាញពីការការពារក្ដីរបស់ខ្លួន។[88]

ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ។

រីឯជនត្រូវចោទជាអនីតិជនចាប់ពីអាយុ ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចមានការលើសពី ៦ (ប្រាំមួយ) ខែបានទេ។[89]

**<u>ប្រសិនបើជាប់ចោទពីបទមជ្ឈិម៖</u>** ករណីជនត្រូវចោទជានីតិជន រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នគឺ ៤ (បួន) ខែ ហើយអាចពន្យារពេលបានតែម្ដងគត់ហើយមិនលើសពី ២ (ពីរ) ខែ ទោះបីជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[90] ឧ. ជនត្រូវចោទជាប់ចោទពីបទអំពើលួច ដែលតាមច្បាប់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣ (បី) ឆ្នាំ។[91] ដែលអប្បបរមានៃទោសគឺ ៦ (ប្រាំមួយ) ខែ ពាក់កណ្ដាលនៃអប្បបរមាគឺ ៣ (បី) ខែ ហេតុនេះមានន័យថាការឃុំខ្លួនជាបណ្ដោះអាសន្នមិនត្រូវលើសពី ៣ (បី) ខែ ឡើយ។

ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែបានទេ ហើយទោះបីជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។

ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ យ៉ាងណារយៈពេលនៃការឃុំ

[88] មាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[89] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[90] មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[91] មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០។

ខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[92]

**ប្រសិនបើជនជាប់ចោទពីបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ៖** ការឃុំខ្លួនមិនឲ្យលើសពី ១ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតចិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានម្ដង ១ឆ្នាំ ដោយដីកាមានសំអាងហេតុ ហើយការពន្យារពេលនេះអាចធ្វើបានតែពីរដងគត់។[93] សរុបមកចិរវេលានៃការឃុំខ្លួនក្នុងបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ មានចិរវេលាយូរជាងគេ គឺការឃុំខ្លួនបណ្ដោះអាសន្នចំនួន ៣ឆ្នាំហើយចំពោះនីតិវិធីនៃការពន្យារពេលមានលក្ខណៈដូចគ្នាទៅនឹងករណីខាងលើដែរ។

### ២. ការត្រួតពិនិត្យតាមផ្លូវច្បាប់តុលាការ

ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវច្បាប់តុលាការ មានន័យថាតុលាការនឹងចាប់ផ្ដើមស៊ើបអង្កេតលើរឿងក្ដី ឬ លើជនត្រូវចោទនោះដើម្បីពិនិត្យមើលថាជននោះពិតជាមានពិរុទ្ធភាពដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាឬទេ។ ដោយចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យ ដាក់ជនត្រូវចោទនៅក្រៅឃុំឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាជម្រើសមួយ ក្រៅពីការឃុំខ្លួនបណ្ដោះអាសន្ន។ ការត្រួតពិនិត្យតាមផ្លូវតុលាការអាចអនុវត្តទៅបានតែក្នុងករណី ដែលជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារប៉ុណ្ណោះ។

#### ២.១. លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវច្បាប់តុលាការ

ទោះបីជាជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវឃុំខ្លួនបណ្ដោះអាសន្នក៏ពិតមែន ប៉ុន្តែក៏នូវតែត្រូវគោរពតាមលក្ខខណ្ឌមួយ ឬ ច្រើនដែលបានកំណត់ដោយចៅក្រមស៊ើបសួរថា:

១.មិនត្រូវចេញក្រៅព្រំប្រទល់ដែនកំណត់ដោយចៅក្រមស៊ើបសួរ។

[92] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[93] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

២.មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥.ត្រូវឆ្លើយតបនឹងការកោះហៅ ពីគ្រប់បុគ្គលដែលចាត់តាំងដោយ ចៅក្រមស៊ើបសួរ។

៦.ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧.មិនត្រូវបើកបរ។

៨.មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩.ដាក់ប្រាក់ធានាថែម ចំនួនប្រាក់ធានា និង ថិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០.មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១.ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។[94]

### ២.២. បុគ្គលដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

បុគ្គលដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគឺ ចំពោះអនីតិជនដែលស្ថិតនៅក្រោមអាយុ ១៤ឆ្នាំ ដោយយោងតាមមាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន

[94] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ចែងយ៉ាងច្បាស់ថា អនីតិជនអាយុតិចជាង ១៤ឆ្នាំ មិនអាចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ។[95]

**២.៣. អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

អានុភាពរបស់ចៅក្រមស៊ើបសួរ នៅក្នុងការត្រួតពិនិត្យតាមផ្លូវតុលាការ គឺអាចធ្វើការសម្រេចកែប្រែ ឬលុបចោលបានតាមគំនិតរបស់ខ្លួន ឬតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា ឬតាមបណ្តឹងសុំរបស់ជនត្រូវចោទ។ ប៉ុន្តែប្រសិនបើជនត្រូវចោទគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារ ដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជា ជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមានៃការឃុំខ្លួនក៏ដោយ។ កាលណាចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និង ទទួលការកត់សំគាល់របស់ជននោះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមធ្យោបាយការពារក្តីរបស់ខ្លួន។ ដោយដីកាសម្រេចនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រានេះមិនអាចឲ្យលើសពី ៤ (បួន) ខែបានទេ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន។[96]

[95] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[96] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

# ជំពូកទី៤ ការបិទការស៊ើបសួរ

## ផ្នែកទី១. ការត្រៀមបញ្ចប់នីតិវិធីនៃការបិទការស៊ើបសួរ

ចំពោះការត្រៀមបញ្ចប់នីតិវិធីនៃការបិទការស៊ើបសួរ គឺជានីតិវិធីមួយដែលចៅក្រមស៊ើបសួរធ្វើមុននឹងឈានដល់នីតិវិធីនៃការបិទបញ្ចប់នៃការស៊ើបសួរ។

### ១. ការជូនពត៌មាននៃការបិទការស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរអាចធ្វើសេចក្ដីសម្រេចបិទបញ្ចប់នីតិវិធីនៃការស៊ើបសួរបាន ដោយជូនដំណឹងនេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីចំពោះការបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន។[97]

### ២. ការពិនិត្យលើសំណុំរឿងដោយព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចធ្វើការពិនិត្យលើសំណុំរឿងស៊ើបសួរ ឬ ស្នើសុំឲ្យបញ្ជូនសំណុំរឿងមកពិនិត្យបានគ្រប់ពេលវេលា ប៉ុន្តែព្រះរាជអាជ្ញាត្រូវមានភារៈកិច្ចបង្វិលសំណុំរឿងនោះទៅវិញ នៅក្នុងចិរវេលា ២៤ (ម្ភៃបួន) ម៉ោង។[98] ក្រោយពីបានពិនិត្យលើសំណុំរឿង បើព្រះរាជអាជ្ញាយល់ឃើញថានៅក្នុងនីតិវិធីស៊ើបសួរ នៅមានកិច្ចមួយចំនួនដែលមិនទាន់ចប់សព្វគ្រប់ ឬ នៅមានកិច្ចណាមួយដែលមិនទាន់បានធ្វើការស៊ើបសួរ ហើយព្រះរាជអាជ្ញាយល់ឃើញថាមានប្រយោជន៍ដល់នីតិវិធីនៃការស៊ើបសួដែរ នោះព្រះរាជអាជ្ញាក៏អាចធ្វើការស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរលើកិច្ចដែលខ្លួនយល់ឃើញថាមានប្រយោជន៍បាន។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមការស្នើសុំឲ្យបំពេញកិច្ចនោះទេចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ចំពោះដីកានេះ ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់

[97] មាត្រា ២៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[98] មាត្រា ១៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[99]

លើសពីនេះទៅទៀត ចំពោះការស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរ គឺមិនមែនមានតែព្រះរាជអាជ្ញាទេដែលអាចធ្វើបានជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចធ្វើបានដែរ។ ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ គឺបានចែងយ៉ាងច្បាស់អំពីសិទ្ធិក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅចៅក្រមស៊ើបសួរ ដោយជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនៅក្នុងចំណុចនោះ គឺមានចែងនៅក្នុងមាត្រា ១៣៣ (ការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ) និងមាត្រា ១៣៤ (ការស្នើសុំឲ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី)។

### ៣.សេចក្ដីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរ ក្រោយពីបានទទួលការជូនដំណឹងរបស់ចៅក្រមស៊ើបសួរស្ដីពីការបិទបញ្ចប់នៃកិច្ចស៊ើបសួរ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ហើយក្រោយពីបានស៊ើបសួរបន្ថែមចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានពីការបិទការស៊ើបសួរម្ដងទៀត។ កាលណាបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ថាការស៊ើបសួរត្រូវបានបញ្ចប់ នោះព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់មកជាមួយផងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បើជនត្រូវចោទត្រូវឃុំខ្លួន និងរយៈពេល ១ (មួយ) ខែ បើជនត្រូវចោទនៅក្រៅឃុំ គិតចាប់ពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលការជូនដំណឹង របស់ចៅក្រមស៊ើបសួរស្ដីពីការបិទបញ្ចប់នៃកិច្ចស៊ើបសួរ។ ដីកាសន្និដ្ឋានស្ថាពរត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងមានសំអាងហេតុ ហើយនៅក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។[100]

---

[99] មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[100] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

## ផ្នែកទី២. ការបិទបញ្ចប់នីតិវិធីស៊ើបសួរ

### ១. ដីកាដំណោះស្រាយ

ដីកាដំណោះស្រាយ គឺជាដីកាដែលចៅក្រមស៊ើបសួរត្រូវធ្វើតែក្រោយពីទទួលបានដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ហើយដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។

#### ១.១. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

នៅត្រង់ចំនុចនេះ ដូចដែលយើងបានដឹងហើយថា ក្រោយពីចៅក្រមស៊ើបសួរទទួលបានដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ហើយដីកានេះអាចជាដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងការចោទប្រកាន់។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា មានបន្ទុកគ្រប់គ្រាន់ពីអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចបញ្ជូនរឿងទៅមុខតុលាការជំនុំជម្រះ ហើយដីកានេះត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។[101] ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។[102] កាលណាចៅក្រមស៊ើបសួរចេញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ នោះសមត្ថកិច្ចរបស់គាត់គឺត្រូវបានបញ្ចប់ ហើយអ្នកដែលមានសមត្ថកិច្ចបន្តទៀតនោះ គឺចៅក្រមជំនុំជម្រះដែលប្រធានតុលាការបានប្រគល់សិទ្ធិឲ្យធ្វើការជំនុំជម្រះ។

#### ១.២. ដីកាសម្រេចលើកលែងការចោទប្រកាន់

ចំពោះដីកាសម្រេចលើកលែងការចោទប្រកាន់នេះ ចៅក្រមស៊ើបសួរអាចចេញក្នុងករណីដូចតទៅ៖

- អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

[101] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[102] មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។[103]

គួរកត់សំគាល់ផងដែរថា ចំពោះដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចគោរពតាមឡើយ ដូច្នេះមានន័យថា ចៅក្រមស៊ើបសួរមានសិទ្ធិអំណាច ក្នុងការសម្រេចចេញដីកាដំណោះស្រាយដោយឯកឯង។ ករណីដែលព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីការជំទាស់ទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ គឺពួកគេមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរបាន។ ប៉ុន្តែចំពោះ ជនត្រូវចោទអាចប្តឹងចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តែសេចក្តីសម្រេចដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការនៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ប៉ុណ្ណោះ។[104]

**២. អានុភាពនៃដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរក្រោយពីទទួលបាននូវ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ហើយដីកានោះវាមានអានុភាពបញ្ចប់នូវ៖ **ការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ**។

**ការបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន៖** គឺមានន័យថាជនត្រូវចោទត្រូវបានដោះលែងអោយមានសេរីភាពវិញ ក៏ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការបាន តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ។ ដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។ សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងការឃុំជាបណ្តោះអាសន្ន នឹងលែងមានអានុភាពក្នុងរយៈពេល ៤ (បួន) ខែ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការ នោះមានន័យថាជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។

---

[103] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[104] មាត្រា ២៦៦, ២៦៧, ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

**ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ៖** គឺមានន័យថា ជនត្រូវចោទបញ្ចប់ពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចរក្សាទុកជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួនមុខតុលាការបានដែរ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ។[105]

## ផ្នែកទី៣. មោឃភាពនៃការស៊ើបសួរ

### ១. មោឃភាពនៃការមិនគោរពបទបញ្ញត្តិ

នីតិវិធីនៃការស៊ើបសួរជាកិច្ចមួយដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ដូចដែលពួកខ្ញុំបានធ្វើការបកស្រាយពីខាងលើរួចមកហើយអំពីសិទ្ធិ និងអំណាចជាច្រើនរបស់ចៅក្រមស៊ើបសួរ ហើយនៅក្នុងកិច្ចស៊ើបសួរនេះ ចៅក្រមស៊ើបសួរត្រូវតែគោរពទៅតាមវិធានបទបញ្ញត្តិដែលច្បាប់បានកំណត់ប្រសិនបើមិនដូច្នេះទេ នឹងនាំឲ្យមានមោឃភាពនៃកិច្ចស៊ើបសួរនោះ។ ចំពោះលក្ខខណ្ឌដែលចៅក្រមស៊ើបសួរត្រូវគោរពតាមនោះមានដូចតទៅ៖

- ការស៊ើបសួរត្រូវតែធ្វើដាច់ខាតចំពោះបទឧក្រិដ្ឋ ប៉ុន្តែចំពោះបទមជ្ឈិមអាចធ្វើការស៊ើបសួរក៏បាន មិនធ្វើក៏បាន (មាត្រា ១២២)។
- ការស៊ើបសួរដោយខុសទៅនឹងសមត្ថកិច្ចដែនដី (មាត្រា ១២៣)។
- ការស៊ើបសួរដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ របស់ព្រះរាជអាជ្ញា (មាត្រា ១២៤ កថាខណ្ឌទី៣)។
- ការស៊ើបសួរទៅលើអង្គហេតុ ដែលមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា (មាត្រា ១២៥ កថាខណ្ឌទី១ និង ទី២)។
- ការស៊ើបសួរដោយពុំមានក្រឡាបញ្ជីអម ឬការឲ្យក្រឡាបញ្ជីបំពេញកិច្ចស៊ើបសួរជំនួសចៅក្រម (មាត្រា ១២៨)។
- ការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ ជាពិសេសគឺវិធានដែលមានបំណងធានា

[105] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ការគោរពសិទ្ធិការពារខ្លួន។ ឧទាហរណ៍: ការសួរចម្លើយជនត្រូវចោទជាអនីតិជន ដោយពុំមានមេធាវីអម (មាត្រា ១៤៣ កថាខណ្ឌទី៤)។

និយាយជារួមមកលក្ខខណ្ឌដែលបានរៀបរាប់ខាងលើនេះ ចៅក្រមស៊ើបសួរដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធីស៊ើបសួររបស់ខ្លួន។[106]

**២. ការប្តឹងទៅសភាស៊ើបសួរ**

ការប្តឹងទៅសភាស៊ើបសួរ គឺជាការប្តឹងដើម្បីឲ្យសភាស៊ើបសួរពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី។ អ្នកដែលមានសិទ្ធិប្តឹងទៅសភាស៊ើបសួរឲ្យពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធីរួមមាន៖ **ចៅក្រមស៊ើបសួរខ្លួនឯង ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី**។

**-ចៅក្រមស៊ើបសួរ៖** ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួរនេះប្តឹងទៅសភាស៊ើបសួរឲ្យពិនត្យមោឃភាពនៃលិខិតនៃនីតិវិធីតាមដីកាដោយមានសំអាងហេតុ និងជូនពត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

**-ព្រះរាជអាជ្ញា៖** ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញាត្រូវធ្វើពាក្យសុំឲ្យពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធីដោយមានសំអាងហេតុ រួចបញ្ជូនទៅសភាស៊ើបសួរ និងជូនពត៌មានដល់ចៅក្រមស៊ើបសួរ។

**-ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី៖** ប្រសិនបើ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព សាមីជនត្រូវធ្វើពាក្យសុំឲ្យពិនត្យមោឃភាពនៃលិខិតនៃនីតិវិធី ដោយមានសំអាងហេតុជូនទៅសភាស៊ើបសួរ និងជូនដំណឹងដល់ចៅក្រមស៊ើបសួរ។ ពាក្យសុំអាចធ្វើដោយមេធាវីរបស់ជនត្រូវចោទ ឬរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ពាក្យសុំនោះនឹងត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើប

[106] មាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

សួរ ហើយក្រឡាបញ្ជីនឹងសុំឲ្យចៅក្រមស៊ើបសួរ បញ្ជូនសំណុំរឿងនៃនីតិវិធីមកឲ្យខ្លួនភ្លាម។[107]

ក្រោយពីសភាស៊ើបសួរ ទទួលបានពាក្យបណ្តឹងសុំឲ្យពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធីរួច សភាស៊ើបសួរអាចចេញសេចក្តីសម្រេចដូចជា: សេចក្តីសម្រេចប្រកាសមិនទទួលពាក្យប្តឹងសុំមោឃកម្ម និងសេចក្តីសម្រេចថាមានមោឃកម្មលើលិខិតនៃនីតិវិធី។

- សេចក្តីសម្រេចប្រកាសមិនទទួលពាក្យប្តឹងសុំមោឃកម្ម ក្នុងករណីដូចតទៅ៖

  -ពាក្យប្តឹងសុំគ្មានសំអាងហេតុ

  -ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន

  -ពាក្យប្តឹងសុំគ្មានមូលភាពយ៉ាងជាក់លាក់។[108]

- សេចក្តីសម្រេចថាមានមោឃកម្មលើលិខិតនៃនីតិវិធីក្នុងករណីនេះ កិច្ច ឬលិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ហើយប្រសិនបើមានការប្រកាសមោឃកម្មសភាអាច៖

  -បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ

  -ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ទៀត

  -បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងក្តីនោះ។[109]

កាលណាសភាស៊ើបសួរសម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯង នោះសភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិករបស់ខ្លួនម្នាក់ឲ្យប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ ប៉ុន្តែសមាជិកនេះពុំមានសិទ្ធិអំណាចទាក់ទិននឹងការបិទការស៊ើបសួរទេ។ ក្រោយពីបញ្ចប់ការ

[107] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[108] មាត្រា ២៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[109] មាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ស៊ើបសួរហើយ ប្រធានសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការ ដើម្បីសម្រេចសាលដីកាដំណោះស្រាយតាមមាត្រា ២៤៧ (ដីកាដំណោះស្រាយ) ដល់មាត្រា ២៥០ (ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ប្រសិនបើសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចរបស់សភាស៊ើបសួរគឺមានអានុភាពអនុវត្តភ្លាម។[110] សេចក្តីសម្រេចរបស់សភាស៊ើបសួរ គឺមិនអាចតវ៉ាបានទេ។[111]

គួរកត់សំគាល់ផងដែរថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ គឺពុំមានបទបញ្ញត្តិណាមួយដែលបានចែងកំណត់អំពីរយៈពេល នៃការប្តឹងសុំមោឃភាពកិច្ច ឬលិខិតនៃនីតិវិធីទេដូច្នេះមានន័យថា ការប្តឹងសុំនេះអាចធ្វើពេលណាក៏បាន ប៉ុន្តែត្រូវធ្វើមុនពេលដែលដីកាដំណោះស្រយចូលជាស្ថាពរ ព្រោះថាដីកាដំណោះស្រាយដែលចូលជាស្ថាពរ នាំឲ្យលុបលាងមោឃភាពនៃនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃភាពណាមួយ នៃនីតិវិធីមុនអាចត្រូវលើកឡើងនៅចំពោះមុខតុលាកាជំនុំជម្រះបានទៀតឡើយ។[112]

**៣. ការលះបង់ការទាមទារមោឃភាពដោយភាគី**

កាលណាការសុំមោឃភាពមានការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍នៃភាគី (ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី) ណាមួយភាគីនោះអាចបោះបង់ដោយមិនលើកយកមោឃភាពមកសំអាងហេតុ ហើយភាគីនោះអាចប្តូរពីការសុំមោឃភាព ទៅជាការកែប្រែនីតិវិធីនោះឲ្យមានភាពប្រក្រតីឡើងវិញ។ ចំណែកការបោះបង់របស់ភាគីនេះ គឺត្រូវនៅក្នុងកំណត់ហេតុដែលពិនិត្យដោយចៅក្រមស៊ើបសួរ។ ក្នុងករណីដែលភាគីមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិច ៥ (ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ ហើយនៅក្នុងរយៈពេលនោះ មេធាវីអាចពិនត្យសំណុំរឿងនៃនីតិវិធីបាន។[113]

---

[110] មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[111] មាត្រា ២៧៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[112] មាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[113] មាត្រា ២៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ៤. ការបើកការស៊ើបសួរលើបន្ទុកថ្មី

ការបើកការស៊ើបសួរលើបន្ទុកថ្មី គឺជាចំនុចមួលដែលពុំសូវមានអ្នកសិក្សាលើកយកមកបកស្រាយ ឬយកមកពន្យល់ឲ្យបានក្បោះក្បាយណាមួយឡើយ ហើយចំពោះក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក៏ពុំបានចែងឲ្យបានច្បាស់លាស់អំពីនីតិវិធីនៃ ការបើកការស៊ើបសួរលើបន្ទុកថ្មីនេះដែរ។ ការបើកការស៊ើបសួរលើបន្ទុកថ្មីនេះ ជានីតិវិធីមួយដែលធ្វើឡើងតាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញាតែម្នាក់គត់។ ចំពោះមូលហេតុដែលនាំឲ្យមានការបើកការស៊ើបសួរលើបន្ទុកថ្មីនេះ គឺក្រោយពីពេលដែលមានដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬ សាលដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរហើយ ក្រោយមកក៏មានលេចឡើងបន្ទុកថ្មី ដែលជាកម្មវត្ថុនៃការស៊ើបសួរនោះការបើកការស៊ើបសួរអាចបើឡើងវិញ តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា។[114]

ចំពោះសំណុំរឿងដែលអាចយកមកបើកការស៊ើបសួរលើបន្ទុកថ្មីនេះបាន លុះត្រាតែការលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរមិនបានធ្វើឲ្យរលត់បណ្តឹងអាជ្ញា មានន័យថា ប្រសិនបើការលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានធ្វើឲ្យរលត់បណ្តឹងអាជ្ញា នោះព្រះរាអាជ្ញាមិនអាចផ្តើមគំនិត បើកការស៊ើបសួរលើបន្ទុកថ្មីបានទេ។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍ច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ៕[115]

[114] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[115] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីក្រុមរបស់យើងខ្ញុំ បានធ្វើការបកស្រាយអំពីប្រធានបទស្តីពី "**ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ(សាលាដម្រះក្តី ខេត្ត-ក្រុង)**" រួចមកយើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា នៅក្នុងនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវធ្វើកិច្ចស៊ើបសួររបស់ខ្លួន ដោយគោរពតាមវិធានបទបញ្ញត្តិដែលកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ហើយប្រសិនបើ ចៅក្រមស៊ើបសួរមិនគោរពតាមវិធានបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ទេនោះ នឹងនាំឲ្យមានមោឃភាពនៃកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ នៅក្នុងនីតិវិធីស៊ើបសួរចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបាន លុះត្រាតែមានបណ្តឹងពីព្រះរាជអាជ្ញា ឬមានបណ្តឹងស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយចៅក្រមស៊ើបសួរ អាចបិទបញ្ចប់នីតិវិធីនៃការស៊ើបសួរបានតាមរយៈដីកាដំណោះស្រាយរបស់ខ្លួន ដែលដីកានោះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចជាច្រើន ដូចជាការចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និងលិខិតបទដ្ឋានជាច្រើនទៀតនៅក្នុងនីតិវិធីនៃការស៊ើបសួររបស់ខ្លួន។

បើទោះបីជាប្រធានបទនេះបានត្រួសត្រាយ នឹងនាំផ្លូវឲ្យអ្នកសិក្សាបានស្វែងយល់កាន់តែច្បាស់ និងស៊ីជម្រៅអំពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរយ៉ាងណាក៏ដោយ ក៏ប្រធានបទនេះពុំអាចបកស្រាយពន្យល់ឲ្យបានសព្វគ្រប់ជ្រុងជ្រោយនូវនីតិវិធីនៃការស៊ើបសួរនេះដែរ។ ម៉្យាងវិញទៀតក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក៏មានចំនុចខ្លះនៅក្នុងនីតិវិធីនៃការស៊ើបសួរ ពុំបានចែងឲ្យបានច្បាស់លាស់ឡើយ ពោលគឺដីកាដែលក្រុមរបស់យើងខ្ញុំបានរៀបរាប់ខាងលើនេះនៅក្នុងក្រមនីតិវីធីព្រហ្មទណ្ឌឆ្នាំ២០០៧ គឺពុំបានចែងឲ្យបានច្បាស់ថា តើដីកាណាមួយ ដែលចៅក្រមស៊ើបសួរត្រូវចេញ មុននៅក្នុងនីតិវិធីរបស់ខ្លួន? ចំពោះការស៊ើបសួរលើបន្ទុកថ្មី ដូចដែលមានចែងក្នុងមាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក៏ពុំបានចែងឲ្យបានច្បាស់លាស់ និងពុំស៊ីជម្រៅទាល់តែសោះ ទើបធ្វើឲ្យអ្នកសិក្សាពិបាកក្នុងការស្វែងយល់ និងមានចម្ងល់នៅត្រង់ចំនុចនេះថា តើនៅពេល

ដែលមានករណីបែបនេះកើតឡើង ការអនុវត្តនីតិវិធីនៃការស៊ើបសួរលើបន្ទុកថ្មី ត្រូវធ្វើឡើងតាមរបៀបណា? មួយវិញទៀត ដូចជាថិរវេលានៃនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ក៏ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ពុំបានចែងឲ្យបានច្បាស់លាស់ដែរ។ ទោះបីជាមានភាពខ្វះចន្លោះបន្តិចមែន ប៉ុន្តែចំពោះប្រធានបទនេះ ក៏ជាផ្នែកមួយដ៏មានសារៈសំខាន់បំផុតសម្រាប់អ្នកសិក្សា ក៏ដូចជាអ្នកដែលចង់ស្វែងយល់ពីចៅក្រមស៊ើបសួរ ឲ្យបានស្វែងយល់កាន់តែច្បាស់ និងស៊ីជម្រៅអំពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ពីមួយដំណាក់កាលទៅមួយដំណាក់កាល។

# អនុសាសន៍

តាមការសិក្សាស្រាវជ្រាវអំពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ យើងសង្កេតឃើញថា នីតិវិធីនេះពិតជាមានភាពល្អប្រសើរខ្លាំងណាស់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ប៉ុន្តែទោះបីជាយ៉ាងណា ក៏នៅតែមានចំនុចមួយចំនួនដែលត្រូវកែប្រែដើម្បីឲ្យមានភាពល្អប្រសើរឡើងវិញផងដែរ និងដើម្បីការពារនូវបញ្ហាប្រឈមដែលកើតមានឡើង នៅពេលអនាគត។ យើងដឹងហើយថា គ្រប់បទល្មើសទាំងអស់មិនមែនសុទ្ធតែអាចស្វែងរកឃើញតាមការស៊ើបសួរ ដើម្បីចាប់ខ្លួនជនល្មើសមកផ្តន្ទាទោសតាមច្បាប់នោះទេ ព្រោះមានករណីខ្លះអាចជួបប្រទះនូវបញ្ហាមួយចំនួនដែលធ្វើឲ្យមានការរាំងស្ទះ នូវដំណើរការនៃនីតិវិធីនៃការស៊ើបសួរ ដូចជាការរាំងស្ទះដោយសារការខ្វះភស្តុតាងដាក់បន្ទុក ខ្វះឧបករណ៍បច្ចេកទេសដើម្បីធ្វើការស្រាវជ្រាវ ខ្វះអ្នកជំនាញដើម្បីធ្វើកោសលវិច្ច័យ។ ប្រសិនបើយើងក្រឡេកទៅមើលករណីមួយទៀត ការជួបប្រទះនូវបញ្ហាអាចបណ្តាលមកពីខ្វះការយកចិត្តទុកដាក់ពីបុគ្គលដែលមានសមត្ថកិច្ចក្នុងការដោះស្រាយរឿងក្តី ពោលគឺចៅក្រមស៊ើបសួរដែលនាំឲ្យនីតិវិធីនៃការស៊ើបសួរមានភាពយឺតយ៉ាវ ឬបញ្ហានយោបាយ ឬអំពើពុករលួយដែលកើតឡើងក្នុងសង្គមដែលធ្វើឲ្យអ្នកដែលប្រព្រឹត្តិនូវបទល្មើសរួចផុតពីការទទួលខុសត្រូវ ហើយអ្នកដែលរងគ្រោះទទួលរងនូវភាពអយុត្តិធម៌។ ម៉្យាងវិញទៀត ចំពោះវិធានការនិរន្តរាយដែលតម្រូវឲ្យមានការឃុំខ្លួនជនត្រូវចោទ ឬ ដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវអនុវត្តន៍ក្របកទៅដោយការពិចារណាខ្ពស់ ព្រោះត្រង់ចំនុចនេះវាបណ្តាលឲ្យមានការប៉ះពាល់ដល់សិទ្ធ និងសេរីភាពជាមូលដ្ឋានរបស់ជនត្រូវចោទ។

ដូចដែលយើងបានដឹងហើយថាចំពោះការអនុវត្ត និងទ្រឹស្តីរមែងតែងតែមិនដូចគ្នាទាំងស្រុងនោះទេ ដូច្នេះនៅត្រង់ចំនុចនេះក្រុមរបស់យើងខ្ញុំសូមធ្វើការសំណូមពរទៅដល់មន្ត្រីដែលមានសមត្ថកិច្ចក្នុងការអនុវត្តនៃនីតិវិធីនៃការស៊ើបសួរ ពោលគឺចៅក្រមស៊ើបសួរសូមបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយភាពយុត្តិធម៌ និងប្រកបដោយវិជ្ជាជីវៈ។ លើសពីនេះទៅទៀត ក្រុមយើងខ្ញុំសូមសំណូមពរទៅដល់មន្ត្រីទាំងអស់ មិនថាតែចៅក្រមស៊ើបសួរនោះទេ ពោលគឺទៅដល់មន្ត្រីដែលមានសមត្ថកិច្ចនៅក្នុងរឿងក្តីព្រហ្មទណ្ឌ សូមបំពេញ

ភារកិច្ចរបស់ខ្លួនប្រកបដោយភាពយុត្តិធម៌ និងប្រកបទៅតាមវិជ្ជាជីវៈរបស់ខ្លួន ដើម្បីធ្វើជាសសរដ៏រឹងមាំមួយសម្រាប់ប្រជាពលរដ្ឋពឹងពាក់អាស្រ័យ នៅពេលដែលពួកគាត់ជួបបញ្ហាអ្វីមួយ ព្រោះយើងដឹងហើយថានៅពេលដែលប្រជាពលរដ្ឋមានបញ្ហា គឺពួកគាត់តែតែងប្ដឹងមកតុលាការ ដើម្បីឲ្យតុលាការធ្វើការដោះស្រាយទៅលើបញ្ហាដែលពួកគាត់កំពុងជួបប្រទះ តែប្រសិនបើតុលាការធ្វើការដោះស្រាយដោយមិនមានភាពយុត្តិធម៌ និងមិនប្រកបទៅតាមវិជ្ជាជីវៈរបស់ខ្លួននោះទេ នោះនឹងធ្វើឲ្យប្រជាពលរដ្ឋបាត់បង់នូវទំនុកចិត្ត លើតុលាការ។ ដូច្នេះក្នុងនាមយើងជាប្រជាពរដ្ឋខ្មែរ យើងត្រូវតែគោរពទៅតាមច្បាប់ធរមាន លើកស្ទួយវិស័យច្បាប់ និងធ្វើខ្លួនឲ្យជាមនុស្សល្អមួយក្នុងសង្គមជាតិដើម្បីរក្សានូវកិត្តិយស ក៏ដូចជាសេចក្ដីថ្លៃថ្នូររបស់ខ្លួន៕

# ឯកសារយោង


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣។
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០។
- ច្បាប់ស្ដីពីពិសោធនកម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០១៤។
- ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។
- សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០១៤។

## សៀវភៅ

- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត. ២០១៦. *នីតិវិធីព្រហ្មទណ្ឌ*. ភ្នំពេញ។
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា. ២០១៣. *នីតិវិធីមុនការជំនុំជម្រះ និងការជំនុំជម្រះ*. ភ្នំពេញ. http://www.sithi.org ។
- សុក សំអឿន. ២០១៥. *ការដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យរបស់តុលាការ*. ភ្នំពេញប៉ុស្ដិ៍, ០៩ មករា, https://m.postkhmer.com(បានចូលមើលចុងក្រោយ ១៨ មិថុនា២០១៨)។
- សេចក្ដីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

## ឧបសម្ព័ន្ធ

- ការបើកការស៊ើបសួរ
- សមត្ថកិច្ចស្រាវជ្រាវផ្ទាល់របស់ចៅក្រមស៊ើបសួរ
- វិធានការនិរន្តរាយ
- ការបិទការស៊ើបសួរ